# សម្ភាសន៍ជាមួយ អ៊ុង វ៉ែន ភេទប្រុស អាយុ៧០ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ ប្រធានវរសេនាធំ៨២

## ស្រុកកំណើតនៅភូមិតាំងពោធិ៍ ឃុំ៨មុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ

## រស់នៅភូមិផ្អៀកជ្រុំ ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ ឡុង ដានី

## ០២:០៧:១២

## ៥៩ទំព័រ

ដានីៈ អីចឹងដំបូងខ្ញុំចង់ស្គាល់ឈ្មោះលោកអ៊ំ ឈ្មោះពេញ ឈ្មោះអីដែរ ។

វ៉ែនៈ ឈ្មោះ អ៊ុង វ៉ែន ហ្នឹង ។

ដានីៈ អ៊ុង វ៉ែន?

វ៉ែនៈ បាទ!

ដានីៈ លោកអ៊ំមានឈ្មោះអីផ្សេងទៀតដែលអត់?

វ៉ែនៈ អត់ទេ ។

ដានីៈ សព្វថ្ងៃអ៊ំអាយុប៉ុន្មានហើយ?

វ៉ែនៈ ប្រហែលជា៧០ហើយ ។

ដានីៈ កើតឆ្នាំអីដែល ឆ្នាំខ្មែរយើង?

វ៉ែនៈ ឆ្នាំវក ។

ដានីៈ ហើយអ៊ំស្រីគាត់ឈ្មោះអីដែរ?

វ៉ែនៈ ភឿក រ័ត្ន ។

ដានីៈ ភឿក ហ៎?

វ៉ែនៈ បាទ!

ដានីៈ គាត់អាយុប៉ុន្មានដែលហើយ?

វ៉ែនៈ ភ្លេចមិនបានទេ ។

ដានីៈ ប្អូនអ៊ំប៉ុន្មានឆ្នាំ ឬក៏បង?

វ៉ែនៈ ប្អូនទេ ។

ដានីៈ ប៉ុន្មានឆ្នាំទៅប្រហែល?

វ៉ែនៈ ប្រហែលខ្ទង់៩០ ។

ដានី៖ អ៊ំមានកូនចៅប៉ុន្មាននាក់ដែរ?

វ៉ែន៖ ៨ ។

ដានី៖ អ៊ំមានគ្រួសារតែមួយហ្នឹង ឬមានមុនទៀត?

វ៉ែន៖ មុនមួយតាំងពីឃួនវ៉ៃកាលនោះរត់ដាច់គ្នាទៅ ។

ដានី៖ កាលពីមុនបែកគ្នា កាលពីឆ្នាំ៧៩ឃួនចូល?

វ៉ែន៖ បាទ!

ដានី៖ ហើយគ្រួសារមុនគាត់នៅ ឬស្លាប់ហើយ?

វ៉ែន៖ មិនដឹងជានៅ តែដាច់គ្នាយូរហើយ ។

ដានី៖ កាលពីមុនមានកូនចៅដែលអត់?

វ៉ែន៖ មានមួយ ។

ដានី៖ មានកូនមួយនៅដែលអត់ទេ?

វ៉ែន៖ នៅតែទៅជាមួយម៉ែវានោះ ។

ដានី៖ នៅជាមួយម្ដាយ នៅខាងស្រុកណាដែរ?

វ៉ែន៖ ពើក ។

ដានី៖ បាទ?

វ៉ែន៖ នៅពើក ។

ដានី៖ ពើកហ្នឹងនៅក្នុងស្រុកអីគេ?

វ៉ែន៖ ព្រះវិហារ ។

ដានី៖ ខាងខេត្តព្រះវិហារ ។

វ៉ែន៖ បាទ!

ដានី៖ ដល់ពេលបានជាមួយអ៊ំស្រីក្រោយបានកូន៨ទៀត?

វ៉ែន៖ បាទ!

ដានី៖ ៨នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មានទៅអ៊ំ?

វ៉ែន៖ ស្រី១ ប្រុស៣ ។

ដានី៖ ធំៗហើយ?

វ៉ែន៖ បាទ!

ដានី៖ គាត់បានរៀនសូត្រអីដល់ណាដែរកូនលោកអ៊ំ?

វ៉ែន៖ មួយបានថ្នាក់ទី៦ មួយបានថ្នាក់ទី៩ ។

ដានី៖ ក្រៅពីហ្នឹងអត់បានរៀនទេ?

វ៉ែន៖ អត់បានរៀនទេ ថ្នាក់ទី៣ៗ ។

ដានី៖ ចុះអ៊ំសព្វថ្ងៃរស់នៅភូមិ-ឃុំអីដែរ? សព្វថ្ងៃនេះ?

វ៉ែន៖ ភូមិផ្តៀកជ្រៃ ឃុំផ្លាវ ។

ដានី៖ ស្រុកត្រពាំងប្រាសាទ?

វ៉ែន៖ បាទ!

ដានី៖ អ៊ំស្រុកកំណើតជាអ៊ំនៅណាទៅ?

វ៉ែន៖ ៨មុំ តាំងពោធិ៍ ។

ដានី៖ ហ្នឹងគេហៅភូមិ?

វ៉ែន៖ ភូមិ៨មុំ ។

ដានី៖ ឃុំតាំងពោធិ៍?

វ៉ែន៖ អត់ទេ ភូមិតាំងពោធិ៍ ឃុំ៨មុំ ។

ដានី៖ ស្រុក?

វ៉ែន៖ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។

ដានី៖ ហើយអ៊ំមានបងប្អូនប៉ុន្មាននាក់ដែរ?

វ៉ែន៖ ៨នាក់ ។

ដានី៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

វ៉ែន៖ មិនដឹងប៉ុន្មានទេ តែស្លាប់ខ្ញុំមកឃូរហើយ ។

ដានី៖ បងប្អូនអ៊ំ៨នាក់ហ្នឹង មានស្រីប៉ុន្មាននាក់ ប្រុសប៉ុន្មាននាក់ទៅ?

វ៉ែន៖ ស្រី៣ ប្រុស៥នាក់ ។

ដានី៖ ហើយអ៊ំកូនទីប៉ុន្មានទៅ?

វ៉ែន៖ ខ្ញុំកូនទី៣ ។

ដានី៖ ឪពុកអ៊ំគាត់ឈ្មោះអីទៅ?

វ៉ែន៖ ខាត់ ។

ដានី៖ គាត់ខូចប៉ុក៏នៅ?

វ៉ែន៖ ស្លាប់ហើយ ។

ដានី៖ គាត់ខូចតាំងពីអង្កាល់ទៅ?

វ៉ែន៖ ៧៩ ។

ដានី៖ គាត់ស្លាប់ដោយសាររោគាពាធ ឬដោយសារអីទៅ?

វ៉ែន៖ ចាស់ជរា ។

ដានី៖ ឆ្នាំ៧៩ ពេលដែលយួនចូលហ្នឹង?

វ៉ែន៖ បាទ!

ដានី៖ គាត់នៅជាមួយអ៊ំដែរឬក៏អត់ទេ?

វ៉ែន៖ អត់ទេ ។

ដានី៖ គាត់នៅខាងស្រុកកំណើត ស្រុកថ្កូវ?

វ៉ែន៖ ស្រុកកំណើត ។

ដានី៖ ចុះម្ដាយ?

វ៉ែន៖ ម្ដាយ៧៨ ។

ដានី៖ ម្ដាយស្លាប់ឆ្នាំ៧៨?

វ៉ែន៖ បាទ!

ដានី៖ ស្លាប់ឆ្នាំ៧៨ដោយសារមូលហេតុអីទៅ?

វ៉ែន៖ គាត់ទៅវិញគាត់ស្លាប់ ។

ដានី៖ គាត់ទៅពីណា?

វ៉ែន៖ គាត់ទៅពីនេះ ជំនាន់អ៊ុនគាក់មិនដឹងឆ្នាំប៉ុន្មាន ។

បូលី៖ ពីត្រពាំងប្រាសាទយើងទៅវិញ?

វ៉ែន៖ បាទ!

ដានី៖ អីចឹងមិនមែន៧៨ទេ?

បូលី៖ ៩៨!

វ៉ែន៖ ហ្នឹងឯង៩៨ ។

ដានី៖ ឪពុកលោកអ៊ំ៧៩ ពេលយួនចូល?

វ៉ែន៖ បាទ!

ដានី៖ ម្ដាយឈ្មោះអីទៅ?

វ៉ែន៖ ស៊ឹម ។

ដានី៖ លោកអ៊ំកាលពីក្មេងៗ បានរៀនសូត្រ ឬបួសរៀន?

វ៉ែន៖ ខ្ញុំបានបួស ។

ដានី៖ បានចូលសាលា?

វ៉ែន៖ បានចូលរៀន ។

ដានី៖ រៀនបានថ្នាក់ទីប៉ុន្មាន? ហើយអាយុប៉ុន្មានបានអ៊ំចូលបួស?

វ៉ែន៖ ថ្នាក់ទី៩ ។

ដានី៖ រៀននៅសាលាណា?

វ៉ែន៖ រៀននៅសាលាតាំងពោធិ៍ហ្នឹង ។

ដានី៖ ដល់ថ្នាក់ទី៩ អ៊ំទៅបួស?

វ៉ែន៖ បាទ! ទៅបួស ។

ដានី៖ បួសនៅវត្តអីគេ?

វ៉ែន៖ បួសនៅវត្តជិតផ្ទះហ្នឹងឯង ។

ដានី៖ គេហៅវត្តអីវត្តហ្នឹង?

វ៉ែន៖ វត្តតាំងពោធិ៍ដែរ ។

ដានី៖ បួសបានប៉ុន្មានវស្សាទៅ?

វ៉ែន៖ គិតទាំងនេនវា៥ឆ្នាំ ។

ដានី៖ អ៊ំបេះធម៌បានច្រើន រៀនសូត្រខាងផ្លូវធម៌បានច្រើនដែរ?

វ៉ែន៖ បាទ!

ដានី៖ បាន៥ឆ្នាំហើយយ៉ាងម៉េចទៀតទៅអ៊ំ?

វ៉ែន៖ សឹកពីបួសមកនៅផ្ទះហ្នឹងឯង ។

ដានី៖ ដល់សឹកពីបួសវិញអ៊ំមកផ្ទះ ឆ្នាំណាដែលអ៊ំសឹកពីបួសហ្នឹង?

វ៉ែន៖ មិនចាំទេយូរហើយ ។

ដានី៖ ដល់ពេលអ៊ំរៀបគ្រួសារឆ្នាំណាទៅ?

វ៉ែន៖ ៧៧ ។

ដានី៖ ៧៧ពេលដែលយើងចូលដល់៣ឆ្នាំហើយ?

វ៉ែន៖ បាទ!

ដានី៖ អីចឹងអ៊ំមកនៅផ្ទះ ហើយអ៊ំចេញពីផ្ទះឆ្នាំណាទៅ? ដូចថាអ៊ំសឹកពីបួសអ៊ំមកនៅផ្ទះជាមួយឪពុកម្ដាយ?

វ៉ែន៖ បាទ!

ដានី៖ ហើយនៅផ្ទះអ៊ំធ្វើអីទៅកាលនៅផ្ទះហ្នឹង?

វ៉ែន៖ ខ្ញុំធ្វើស្រែ ។

ដានី: ដល់ឆ្នាំណាបានអ៊ំចេញពីផ្ទះទៀត?

វ៉ែន: ខ្ទង់៦៨-៦៩ហ្នឹង ។

ដានី: អ៊ំអាចរៀបរាប់កន្លែងហ្នឹងតិច អ៊ំដូចថាឆ្នាំ៦៨-៦៩យ៉ាងម៉េចបានអ៊ំចេញពីផ្ទះ? ហើយចេញទៅធ្វើអីទៅ?

វ៉ែន: ជិតាន់នោះខ្ញុំដឹងថាតស៊ូ គេឲ្យរត់ចូលព្រៃក៏រត់ ដល់ពេលលំបាកពេកខ្ញុំឡប់មកផ្ទះវិញ អត់បាយ អត់ទឹកមកផ្ទះវិញ ។

បូលី: អ្នកណាឲ្យរត់ចូលព្រៃហ្នឹង?

វ៉ែន: អ្នកចាស់ៗនៅភូមិហ្នឹង ។

ដានី: ស្រុកកំណើតអ៊ំជិតអ៊ំ ប៉ូច ដែរ?

វ៉ែន: ជិតគ្នា តែគាត់នៅខាងក្រោមខ្ញុំ ។

ដានី: តែនៅជិតគ្នាហ្នឹង?

វ៉ែន: ឆ្ងាយដែរបើដើរ បើបើកឡានដូចជិតដែរ តែមិនដែលទាក់ទងគ្នាទេ ។

ដានី: ដែលស្គាល់គ្នាដែលកាលនោះ?

វ៉ែន: អត់ទេ ។

ដានី: អត់ដែលស្គាល់ទេ?

វ៉ែន: អត់ ។

ដានី: អ៊ំអាន?

វ៉ែន: តាអាន គាត់នៅកំពង់ឆ្នាំង ។

ដានី: កំពង់ឆ្នាំងតែនៅជាប់គ្នា?

វ៉ែន: អត់នៅជាប់គ្នាទេ ស្គាល់តាមរយៈចូលព្រៃហើយបានស្គាល់គ្នា ។

ដានី: អ៊ំស៊ូ ម៉េត?

វ៉ែន: បាទ! អ៊ំម៉េត គាត់នៅម្តុំ អាន ហ្នឹងដែរ ។

ដានី: នៅម្តុំហ្នឹងដែរ?

វ៉ែន: បាទ!

ដានី: អ៊ំដូចថាចាស់ៗគាត់ឲ្យចូលព្រៃតាមចាស់ ចាស់ៗអ្នកស្រុកអ្នកភូមិហ្នឹង ឬចាស់ៗដែលគាត់អ្នកតស៊ូ នៅក្នុងចលនា?

វ៉ែន: តាមខ្ញុំយល់មិនដឹងអ្នកតស៊ូហ្នឹងយ៉ាងម៉េចទេ គ្រាន់តែគាត់ថាឥឡូវសភាពការណ៍វាចេះៗយើងនាំគ្នាចូលព្រៃតស៊ូតែប៉ុណ្ណឹង ។

ដានី:	អ៊ំចូលទៅខាងណាទៅកាលហ្នឹង?

វ៉ែន:	ខ្ញុំគស៊ូចូលទៅម្តុំឱរ៉ាល់ ។

ដានី:	យើងមានដាកង់ទ័ពនៅពេលយើងចូល?

វ៉ែន:	អត់មានទេ មានតែមួយកន្លែង៨-១០នាក់ប៉ុណ្ណឹងឯង ។

ដានី:	ចេញទៅកន្លែងឱរ៉ាល់ដល់ឆ្នាំណាទៅ បានមានការផ្លាស់ប្តូរយ៉ាងម៉េចទៀត?

វ៉ែន:	ខ្ញុំភ្លេចមិនបានទេ ។

បូលី:	ទៅដំបូងជួបពីណានៅឱរ៉ាល់?

វ៉ែន:	ទេអត់ជួបពីណា ជួបតែអ្នកដែលនាំទៅពីនេះ តែគាត់ស្លាប់អស់ហើយ ។

បូលី:	អ្នកនាំហ្នឹងអ្នកស្រុកអ្នកភូមិដែរ?

វ៉ែន:	អ្នកស្រុកអ្នកភូមិហ្នឹងឯង ។

បូលី:	គេចូលមុនអ៊ំ ឬគេចូលដំណាលអ៊ំ អ្នកនាំ?

វ៉ែន:	ទេ មិនដឹងទេ គ្រាន់តែថាគាត់អ្នកចាស់ទុំ ។

ដានី:	លោកអ៊ំកាលជំនាន់ហ្នឹងបានជួបលោកតា ម៉ា ម៉េង់ ទេ?

វ៉ែន:	អត់ទេ អត់ដែលស្គាល់ លឺតែឈ្មោះគេ ។

ដានី:	ហើយលោកអ៊ំនៅខាងឱរ៉ាល់ហ្នឹងដល់ឆ្នាំណាទៅបានផ្លាស់ទៅទៀត?

វ៉ែន:	តិចគេឲ្យទៅយកគ្រាប់ តិចគេឲ្យទៅនេះ ទៅនោះ មួយថ្ងៃនៅនេះ មួយថ្ងៃនៅនោះ ។

ដានី:	ដល់រដ្ឋប្រហារឆ្នាំ៧០ ពេលលន់ នល់ ធ្វើរដ្ឋប្រហារ ហើយអ៊ំយ៉ាងម៉េចទៀតទៅចលនាមានប្រែប្រួល?

វ៉ែន:	ចាំមើលខ្ញុំនិយាយ មួយរយៈសភាពការណ៍លំបាក ឲ្យទៅនេះផង ទៅនោះផង លំបាកអត់បាយ អត់ទឹកខ្ញុំមកផ្ទះ ដល់អីចឹងដល់ពេលឆ្នាំ៧០រដ្ឋប្រហារ គេអំពាវនាវឲ្យចូលម្តងទៀតចូលទៀត ថាលន់ នល់ ធ្វើរដ្ឋប្រហារសម្តេចសីហនុ ឲ្យចូលមករួបរួមគ្នា ដើម្បីបណ្តេញពួកហ្នឹងការពារសម្តេចសីហនុ ។

បូលី:	៧០ក្រោយរដ្ឋប្រហារចូលម្តងទៀត?

វ៉ែន:	បាទ! ទៅម្តងទៀត ។

បូលី:	ម្តងនេះចូលទៅខាងណាទៀត?

វ៉ែន:	ចូលទៅនៅខាងហ្នឹងដដែល ។

បូលី:	ឱរ៉ាល់ដដែល?

វ៉ែន:	អត់ទេ ចូលនៅផ្ទះ ។

ដានី៖ ចូលនៅផ្ទះហ្នឹងតែម្តង?

វ៉ែន៖ បាទ!

ដានី៖ បានន័យថាខាងស្រុកអ៊ំខាងរំដោះ គ្រប់គ្រងអស់ហើយ?

វ៉ែន៖ បាទ!

ដានី៖ ចូលម្តងទៀតអ៊ំទៅនៅខាងអគ្គភាពណាទៅ?

វ៉ែន៖ ខ្ញុំចូលម្តងទៀតនៅស្រុកភូមិហ្នឹង ដូចថានៅអគ្គភាពជាមួយតាចេង អន ។

ដានី៖ កាលហ្នឹងតាអន គាត់ធ្វើអីទៅ?

វ៉ែន៖ មិនដឹងធ្វើអីទេ គាត់អ្នកទទួលខុសត្រូវ ។

បូលី៖ នៅផ្ទាល់ជាមួយតាចេង អន?

វ៉ែន៖ អត់ទេ គាត់អ្នកហៅធ្វើការមួយភ្លែត ថ្ងៃណាគាត់ហៅមក ។

ដានី៖ កាលហ្នឹងដូចថាយើងធ្វើការជាមួយតាចេង អន គាត់គ្រប់គ្រងកងទ័ព ឬក៏យ៉ាងម៉េចដែល កាលហ្នឹង?

វ៉ែន៖ ពេលនោះគឺថាច្របូកច្របល់ទេ ដូចថារដ្ឋអំណាចផង ទាហានផង ។

ដានី៖ ប៉ុន្តែលោកអ៊ំកាលហ្នឹងនៅខាងទាហាន ឬខាងរដ្ឋអំណាច?

វ៉ែន៖ អត់ទាន់ច្បាស់ទេ តែតាមពិតតាចេង អន មានអីគាត់ហៅមកប្រជុំ អប់រំប្រជាជន កសាងប្រជាជន សភាពការណ៍ចេះៗគាត់ហ្នឹងឯង ។

ដានី៖ លោកអ៊ំតាមលោកអ៊ំស្រមៃមើល តាចេង អន រូបរាងគាត់ម៉េចដែរ?

វ៉ែន៖ រាងស រាងទាប ។

ដានី៖ គាត់ធាត់ ឬស្គម?

វ៉ែន៖ កាលខ្ញុំជួបគាត់ធាត់ ។

ដានី៖ បើប្រៀបធៀបជាមួយបងមិញដែលគាត់ដើរចេញទៅ?

វ៉ែន៖ ប្រហែលហ្នឹង ។

ដានី៖ ប្រហែលបងណាក់?

វ៉ែន៖ ប្រហែលគ្នាហ្នឹងឯង ។

ដានី៖ ក្រៅពីលោកតាចេង អន មានពីណាទៀតដែលធ្វើការជាមួយអ៊ំ? ដូចថាគាត់មកទទួលខុសត្រូវខាងហ្នឹង?

វ៉ែន៖ ជាមួយតាចេង អន មានតាទិតៗ ភូមិភាគខាងជើង?

ដានី៖ ឈ្មោះតាទីប ភាគខាងជើង?

វ៉ែន:	នៅគណៈជាមួយគាត់ តែដឹងថាគាត់នៅភាគខាងជើង គាត់ហ្នឹងខ្មៅ ទាប ។

ដានី:	ឆ្នាំ៧០ លោកអ៊ំនៅជាមួយតាចេង អន ធ្វើដល់ពេលណាទៅបានមានផ្លាស់ប្តូរអីទៀតដែរ?

វ៉ែន:	កាលដែលវៃចូលភ្នំពេញបានបែកពីគាត់?

ដានី:	ដល់ឆ្នាំណាបានបែកពីគាត់?

វ៉ែន:	ខ្ទង់៧៤ហ្នឹងហើយ ។

ដានី:	អីចឹងអ៊ំធ្វើការជាមួយតាចេង អន ពីឆ្នាំ៧០ - ៧៤?

វ៉ែន:	បាទ!

ដានី:	កាលហ្នឹងពី៧០ - ៧៤លោកអ៊ំនៅទទួលរដ្ឋអំណាចផង កងទ័ពផង?

វ៉ែន:	បាទ!

ដានី:	លោកអ៊ំទទួលផ្នែកនៅកន្លែងណាទៅ?

វ៉ែន:	ខ្ញុំនៅម្តុំភ្នំប្រសិត ។

ដានី:	ជាស្រុកឬជាស្អីហ្នឹងកន្លែងភ្នំប្រសិត?

វ៉ែន:	មិនដឹងជាស្រុក ឬជាអីទេ គ្រាន់តែដឹងថាម្តុំភ្នំប្រសិតហ្នឹងឯង ។

ដានី:	កាលហ្នឹងអ៊ំជាមេដឹកនាំ ឬក៏មានអ្នកដឹកនាំពីលើអ៊ំទៀត?

វ៉ែន:	ខ្ញុំមែនទែនដឹងថាតាចេង អន និងតាទឹប ។

ដានី:	តែអ៊ំនៅខាងម្តុំភ្នំប្រសិត?

វ៉ែន:	បាទ!

ដានី:	មានកងទ័ពមានអីនៅជាមួយអ៊ំ?

វ៉ែន:	មិនមែនកងទ័ពអីទេ មានតែ១០ - ២០នាក់នៅជាមួយគ្នា គ្រាន់តែដើរធ្វើការជាមួយប្រជាជន កន្លែងណាតែតឹងតែងខ្ញុំអត់ទៅទេព្រោះអត់មានកំលាំង គាត់ថាឲ្យ១០ - ២០នាក់ជូនទៅ បានទៅធ្វើ ។

ដានី:	ចុះដល់ពេលយើងមានទិសដៅវៃចូលទីក្រុងភ្នំពេញ ពេលហ្នឹងយើងរៀបចំជាកងទ័ព?

វ៉ែន:	រៀបចំហើយ ។

ដានី:	រៀបចំអ៊ំអាចមានប្រសាសន៍កន្លែងហ្នឹងយើងរៀបចំយ៉ាងម៉េច ជាកងទ័ព ឬជាកងពលយ៉ាងម៉េច? ពេលហ្នឹងចាប់ផ្តើមរៀបពីពេលណា?

វ៉ែន:	ខ្ញុំមិនចាំថ្ងៃ មិនចាំឆ្នាំទេ គ្រាន់តែដឹងថាថ្ងៃដែលរៀបចំហ្នឹងគឺហៅថាកងពល១៨ ។

ដានី:	កង១៨រៀបចំតាមគំនិតផ្តួចផ្តើមពីណាគេរៀបចំកងពល១៨ហ្នឹង?

វ៉ែន: ខ្ញុំក្ដាប់អត់បាន គ្រាន់តែតាចេង អន ថាឥឡូវលែងនៅជាមួយខ្ញុំហើយ នៅជាប់ជាមួយកងពលហ្នឹងទៅ ។

ដានី: ពេលដែលលោកអ៊ំទៅនៅកងពល១៤ កងពល១៤គេបង្កើតនៅ?

វ៉ែន: បង្កើតហើយ ។

ដានី: កងពល១៤ សមាសភាពមកពីខាងណាខ្លះ? ដូចថាកងទ័ពមកពីណា?

វ៉ែន: តាមខ្ញុំចាំមកពីខាងត្បូងផ្លូវ ។

ដានី: ខាងត្បូងផ្លូវលេខប៉ុន្មាន?

វ៉ែន: ផ្លូវលេខ៤ ។

ដានី: ខាងត្បូងផ្លូវខាងណាចេះ? ផ្លូវពីភ្នំពេញទៅកំពង់សោម ខាងលិច?

វ៉ែន: ហ្នឹងហើយ ខាងនេះខាងជើង ។

ដានី: ខាងកំពង់ស្ពឺខាងជើង ខាងតាកែវ ខាងត្បូង?

វ៉ែន: បាទ! ហ្នឹងហើយ ។

ដានី: អីចឹងកងទ័ពមកពីខាងត្បូងផ្លូវ?

វ៉ែន: បាទ!

ដានី: កងទ័ពទាំងអស់មកពីខាងត្បូងផ្លូវទាំងអស់?

វ៉ែន: មកពីឧត្ដរមួយកងដែរ ។

ដានី: ខាងត្បូងផ្លូវហើយនិងខាងឧត្ដរមួយកង ។ មួយកងហ្នឹងមួយកងអីគេ? មួយកងវរៈ?

វ៉ែន: អាចវរសេនាធំគេ ។

ដានី: ហើយចុះលោកអ៊ំមានមនុស្សទៅជាមួយចូលក្នុងកងហ្នឹងដែរ? ឬក៏តែអ៊ំទៅទេ?

វ៉ែន: ដល់ពេលរៀបចំកំលាំងពីស្រុកខ្លះមករួមជាមួយគ្នាប្រគល់ឲ្យខ្ញុំរៀបចំ១កង ។

ដានី: មួយកងវរសេនាធំដែរ?

វ៉ែន: បាទ!

ដានី: អីចឹងអ៊ំទៅចូលជាមួយកងពល១៤ហ្នឹងអ៊ំមានកងវរសេនាធំរបស់តំបន់១៥មួយកងដែរ?

វ៉ែន: បាទ!

ដានី: ហើយកងខាងភូមិភាគឧត្ដរមួយកងវរសេនាធំដែរ?

វ៉ែន: បាទ!

ដានី: ហើយកងទ័ពមកពីខាងត្បូងផ្លូវប៉ុន្មានកង?

វ៉ែន: មួយកងដែរ ។

ដានី:	អ៊ីចឹងកងរបស់តំបន់១៥មួយកងវរសេនាធំ, ខេត្តមួយកងវរសេនាធំ អ៊ីចឹងអ៊ំ?

វ៉ែន:	បាទ!

ដានី:	ហើយខាងត្បូងផ្លូវជាតិលេខ?

វ៉ែន:	មួយវរសេនាធំ ។

ដានី:	លោកអ៊ំមានដឹងថាម៉េចបានគេដាក់ឈ្មោះកងពលលេខ១៨អ៊ីចឹង?

វ៉ែន:	ខ្ញុំអត់ដឹងទេ តែគេដាក់អ៊ីចឹង ។

ដានី:	ដឹងតែគេដាក់អ៊ីចឹង កាលហ្នឹងខាងប្រធានកងពលពីណាគេ?

វ៉ែន:	សូ សារឿន ។

ដានី:	សូ សារឿន(០៥)?

វ៉ែន:	ខេត្តរគឺ០៦ តាសាន ។

ដានី:	កងខេត្តរកងរបស់តាសាន?

វ៉ែន:	បាទ!

ដានី:	០៦តាសាន គាត់ឈ្មោះអីទៅឈ្មោះពេញ?

វ៉ែន:	មិនដឹងឈ្មោះអី ។

ដានី:	កងរបស់តាសាន ហ្នឹងកងភូមិភាគខេត្តរ?

វ៉ែន:	បាទ!

ដានី:	ហើយកងតាសារឿន មកពីខាងណា?

វ៉ែន:	ខាងត្បូងផ្លូវ ។

ដានី:	ហើយអ៊ីចឹងប្រធានកងពលឈ្មោះសូ សារឿន(០៥) ហើយតាសាន គាត់ជា?

វ៉ែន:	អនុ ។

ដានី:	មានតែពីរនាក់ហ្នឹងទេ?

វ៉ែន:	បាទ!

ដានី:	អ៊ំអត់មានចូលក្នុងគណៈកងពលទេ?

វ៉ែន:	អត់ទេ ។

ដានី:	ហើយកាលហ្នឹងវាមាន៣វរសេនាធំ?

វ៉ែន:	បាទ!

ដានី:	វរសេនាធំលេខប៉ុន្មានខ្លះទៅ?

វ៉ែន:	សើច ។

ដានី៖ វរសេនាធំរបស់លោកអ៊ំលេខប៉ុន្មានកាលនោះ?

វ៉ែន៖ ខ្ញុំអត់ចាំអស់ទេ ។

ដានី៖ កាលហ្នឹងវាមានជាលេខ១៥, ១៦ ឬលេខប៉ុន្មាន? លេខ៨១, ៨២?

វ៉ែន៖ អាច០ ។

ដានី៖ ៨២ក្រែងទៅរតនគិរី?

វ៉ែន៖ អត់ទេ ។

ដានី៖ អីចឹងវាមានលេខ?

វ៉ែន៖ ៨១,៨២ ។

ដានី៖ ៨១, ៨២, ៨៣ ។ ហើយ៨១ពីណាប្រធាន?

វ៉ែន៖ ៨១ប្រធាន កែវ សារឿន ខ្ញុំចាំតែប៉ុន្មាន ។

ដានី៖ ៨១ហ្នឹងកងទ័ពមកពីខាងណា? ខាងត្បូងផ្លូវជាតិលេខ៨ ឬមកពីខាងណា?

វ៉ែន៖ ៨១ហ្នឹង តែពេលហ្នឹងច្របូកច្របល់ ។

ដានី៖ ច្របល់ចូលគ្នាហើយ?

វ៉ែន៖ បាទ! ស្រេចតែគេរៀបចំ តែតាមពិតក្នុង៨១ហ្នឹងវាមានអ្នកនៅភូមិភាគពិសេសខ្លះ គេហៅថា៨១ ។

ដានី៖ អីចឹងចំរុះរវាងភូមិភាគពិសេសហើយអ្នកណាខ្លះ? ចំរុះជាមួយអ្នកមកពីខាងត្បូងផ្លូវ ឬចំរុះជាមួយពួកមកពីខាងឧត្តរ?

វ៉ែន៖ ពេលនោះបើមកពីខាងត្បូងផ្លូវច្រើនហើយនិងកន្លែង៨១ច្រើន ៨៣តិចដកធ្វើម៉េចឲ្យប្រហាក់ប្រហែលគ្នា តែលេខយកតែ១ ។

ដានី៖ ចុះ៨២?

វ៉ែន៖ ៨២មានខ្ញុំហ្នឹងឯង ។

ដានី៖ អ៊ំជាប្រធានវរសេនាធំ៨២?

វ៉ែន៖ បាទ!

ដានី៖ ហើយ៨២កំលាំងភាគច្រើន?

វ៉ែន៖ កំលាំងភាគច្រើននៅអង្គស្នួល ម៉ុំអមលាំងទៅពីហ្នឹង ហើយដកពី៨១ខ្លះ ៨៣ខ្លះ ។

ដានី៖ វរៈ៨៣?

វ៉ែន៖ វរៈ៨៣មកពីឥសាន ។

ដានី៖ ប្រធានពីណា?

វ៉ែន: ប្រធានធិន ។

ដានី: ឪ ធិន ហ្នឹង?

វ៉ែន: បាទ! ហើយនិងឡី បងប្អូនខាងហ្នឹងហើយ ។

ដានី: ហ្នឹងវរៈ៨៣ភាគច្រើនបងប្អូនជនជាតិមកពីឥសាន?

វ៉ែន: បាទ!

ដានី: កងទ័ពក៏អ៊ីចឹងដែរ?

វ៉ែន: បាទ! តែខ្មែរចំរុះខ្លះ ។

ដានី: អ៊ីចឹងកងពល១៨វាមានចំរុះ មានពីខាងតំបន់១៥, មានមកពីខាងឥសានទៀត?

វ៉ែន: បាទ!

ដានី: ឥសាន, ឧត្តរ ហើយនិងកងទ័ពខាងត្បូងផ្លូវជាតិលេខ៤?

វ៉ែន: បាទ!

ដានី: អ៊ីចឹងវាមាន៤ សមាសភាពបញ្ចូលគ្នា៤?

វ៉ែន: បាទ!

ដានី: ដល់ពេលបង្កើតបានជាកងពលមានសមាសភាពអ៊ីចឹងហើយ កងពលហ្នឹងចាប់ផ្ដើមប្រតិបត្តិការណ៍ពីត្រឹមណាមកត្រឹមណាទៅ? ពេលយើងមានទិសដៅវ៉ៃចូលទីក្រុងភ្នំពេញហ្នឹង?

វ៉ែន: កងពលទាំងអស់ហ្នឹងគឺនៅម្ដុំខាងលិចផ្លូវរទេះភ្លើង ម្ដុំទួលលាភ ។

ដានី: កន្លែងទួលលាភ?

វ៉ែន: បាទ! ម្ដុំទួលលាភ ។

ដានី: កងពលទាំងអស់នៅហ្នឹងទាំងអស់ ឬក៏មាន?

វ៉ែន: នៅតែកងពល១៨ទេ ។

ដានី: កងពល១៨ទួលលាភ ចាប់ពីទួលលាភដល់ត្រឹមណាទៅ? ពីត្រឹមណាដល់ណា?

វ៉ែន: ចាប់ពីទួលលាភទល់ផ្លូវជាតិលេខ៥ ហើយផ្លូវជាតិលេខ៤ ។

ដានី: ខាងភ្នំប្រសិទ្ធិក៏ខាងកងពលលោកអ៊ំ?

វ៉ែន: បាទ!

ដានី: អ៊ីចឹងមានដាន់ជាមួយពួកឧត្តរ?

វ៉ែន: អត់ទេ ឧទាហរណ៍ថាចង់វ៉ៃចូលភ្នំពេញ កន្លែងណាដែលធូរជាងគេដកកងពល រួមជាមួយគ្នាចូលវ៉ៃ ។

ដានី: លោកអ៊ីកន្លែងនេះភ្នំពេញ អ៊ីចឹងនេះផ្លូវជាតិលេខ៥ ហើយនេះផ្លូវជាតិលេខ៤ ហើយកង ពល នេះភ្នំប្រសិទ្ធិនៅកន្លែងនេះ កងពលលោកអ៊ីចូលកន្លែងណាខ្លះ?

វ៉ែន: ខ្ញុំនៅតែម្តុំទួលលាភ ។

ដានី: ទួលលាភនៅខាងណាភ្នំប្រសិទ្ធិ?

វ៉ែន: ខាងត្បូង ។

ដានី: ខាងនេះភ្នំប្រសិទ្ធិ?

វ៉ែន: បាទ!

ដានី: អានេះផ្លូវជាតិលេខ៤ ពោធិ៍ចិនតុងនៅម្តុំៗនេះ ។ អ៊ីចឹងកងពល១៨ចាប់ពីត្រឹមណាដល់ ត្រឹមណា?

វ៉ែន: នេះផ្លូវជាតិលេខ៤?

ដានី: នេះផ្លូវជាតិលេខ៤ ។

វ៉ែន: ចាប់ផ្លូវជាតិលេខ៤ទល់គ្នាផ្លូវជាតិលេខ៥ ។

ដានី: ចុះខាងកងពលខត្តរ កងពលតាអឿន នៅខាងណា?

វ៉ែន: ដូចខ្ញុំបានជំរាបពីខាងដើមអ៊ីចឹង វៃចូលភ្នំពេញលុះគ្រាកន្លែងណាធូរដកកងពលហ្នឹងមកដាក់ ជុំគ្នា វៃហើយបាននៅតាមមុខសញ្ញារបស់ខ្លួនវិញ ។

ដានី: អ៊ីចឹងបានន័យថាម្តុំហ្នឹងក៏យើងអាចថាកងពលចំរុះគ្នាវៃចូលទៅ?

វ៉ែន: បាទ!

ដានី: ប៉ុន្តែកងពលលោកអ៊ីគឺពីផ្លូវលេខជាតិ៥ ដល់ផ្លូវជាតិលេខ៤មានទាំងអស់?

វ៉ែន: បាទ!

ដានី: មានទាំងអស់ចូលមក ។

វ៉ែន: ពីព្រោះពេលហ្នឹងផ្លូវជាតិលេខ៤ និងផ្លូវជាតិលេខ៥ តែវាចែកតាមវរសេនាធំ គេចែក តាមវរសេនាតូចទៀត ហើយវរសេនាតូចចែកតាមក្រុមទៀត ក្រុមណាជាប់ផ្លូវ ។

ដានី: ចុះវរសេនាធំលោកអ៊ីលេខ៨២នៅម្តុំណា?

វ៉ែន: ដូចខ្ញុំបានបញ្ជាក់មុិញអ៊ីចឹង នៅម្តុំទួលលាភហ្នឹង ។

ដានី: ពេលដែលយើងចាប់ផ្តើមវៃចូលទីក្រុងភ្នំពេញ រយៈពេលប៉ុន្មានដែលយើងវៃដាច់? យើង វៃដាច់ខែ៤ ឆ្នាំ៧៥ យើងចាប់ពីឆ្នាំណា ខែណា ដែលចាប់ផ្តើមវៃចូលទីក្រុងភ្នំពេញ?

វ៉ែន: វៃមួយសារហ្នឹងអត់ថយវិញ ហើយបានទៅវៃទៀត ។

ដានី: អីចឹងលោកអ៊ីកាលយើងវៃចូលខាងភ្នំពេញ កាលហ្នឹងខាងកងទាហានលន់ នល់ កាលហ្នឹង កងពលលេខប៉ុន្មានទៅ ដែលវៃទល់ជាមួយអ៊ី? ដែលប្រឆាំងគ្នា ដូចអ៊ីវៃចូលភ្នំពេញ ហើយលន់ នល់ វៃទប់មក? លោកអ៊ីនៅចាំទេថាកងពលលន់ នល់ ជាកងពលលេខ ប៉ុន្មាន ដែលវៃជាមួយអ៊ី? ប្រឆាំងជាមួយអ៊ី?

វ៉ែន: ខ្ញុំភ្លាប់មិនបានទេរឿងកងពល តែបើបញ្ជាការកងពលគឺភ្លាប់លេខកងពលលេខប៉ុន្មានទល់ លេខប៉ុន្មានភ្លាប់បាន តែខាងខ្ញុំគេចាត់តាំងឲ្យទៅខាងហ្នឹង ទៅហ្នឹង តែកងពលគេតាមដានពី លើ ថាខ្មាំងឈ្មោះអី កងពលលេខប៉ុន្មានតាមឡាន ។ ឥឡូវកងពលនេះមកវៃហើយ វៃ មួយជួរផ្លូវជាតិលេខ៥ ប្រុងប្រៀបប្រយ័ត្នតែប៉ុណ្ណឹងឯង កងពលគេតាមដាន គេភ្លាប់ ។

ដានី: ទាល់តែបញ្ជាការកងពលបានគេដឹង?

វ៉ែន: បាទ! គេដឹង ។

ដានី: តែអ៊ីអត់បានដឹងទេកាលហ្នឹង?

វ៉ែន: អត់ដឹងទេ ។

ដានី: ចុះពេលដែលយើងវៃបានចូលដល់ទីក្រុងភ្នំពេញ កំលាំងរបស់លោកអ៊ីកងពល១៤ វរសេនាធំរបស់លោកអ៊ី ថ្ងៃណាដែលយើងចូលដល់ទីក្រុងភ្នំពេញហ្នឹង? យើងបែកថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥ អីចឹងកំលាំងលោកអ៊ីចូលនៅថ្ងៃណា?

វ៉ែន: ខ្ញុំមកដល់វត្តតាំងក្រសាំងខ្ញុំរបួសហើយ ។

ដានី: ដល់វត្តតាំងក្រសាំងអ៊ីរបួស?

វ៉ែន: បាទ!

ដានី: ត្រូវរបួសកន្លែងណា?

វ៉ែន: ជើងហើយនិងស្មា កន្លែងវែកអំវែក ។

ដានី: ហ្នឹងត្រូវរបួសពេលហ្នឹង? ពេលដែលវៃចូលភ្នំពេញឆ្នាំ៧៥?

វ៉ែន: បាទ!

ដានី: ដល់វត្តតាំងក្រសាំង ដល់ពេលអ៊ីត្រូវរបួសមកសំរាកនៅពេទ្យណាទៅ?

វ៉ែន: ខ្ញុំមកសំរាកនៅពេទ្យនៅមុំវត្តពូនភ្នំ ។

ដានី: វត្តពូនភ្នំនៅក្នុងណាទៅ?

វ៉ែន: មកពីវត្តតាំងក្រសាំងមកបន្តិចមក មានវត្តហ្នឹង មានទំនប់ ។

ដានី: នៅជិតភ្នំពេញដែរ?

វ៉ែន: ជិតភ្នំពេញដែរ ។

ដានី៖ នៅជិតវត្តតាំងក្រសាំង?

វ៉ែន៖ បាទ!

ដានី៖ នៅខាងឃ្នួញ, អន្លង់ក្ងានហ្នឹង?

វ៉ែន៖ ហ្នឹងហើយ ។

ដានី៖ អ៊ីសំរាន្តនៅពេទ្យហ្នឹងបានយូរទេ?

វ៉ែន៖ យូរទាល់តែគេឈ្នះភ្នំពេញបានខ្ញុំចូលទៅភ្លែត ឡប់មកសំរាកហ្នឹងវិញ ។

ដានី៖ ពេលឈ្នះទីក្រុងភ្នំពេញហើយកងពល១៨ទីតាំងនៅកន្លែងណាទៅ? យើងចូលទៅឈរនៅក្នុងទីក្រុងភ្នំពេញ?

វ៉ែន៖ រឿងកន្លែងកងពលខ្ញុំភ្លាប់អត់បានទេ កន្លែងកងពលខ្ញុំភ្លាប់មិនបាន តែវរសេនាធំខ្ញុំគេនៅម្តុំចាប់ពីពហុកីឡាដ្ឋានមកលិចទល់ពេទ្យលោកសង្ឃ ។

ដានី៖ ពីពហុកីឡាដ្ឋានមកដល់ពេទ្យលោកសង្ឃ?

វ៉ែន៖ បាទ!

ដានី៖ ហ្នឹងវរសេនាធំ៨២ បើ៨១នៅខាងណា?

វ៉ែន៖ ៨១អត់ដឹងនៅខាងណាទេ ។

ដានី៖ ៨៣?

វ៉ែន៖ ៨៣ខ្ញុំភ្លាប់មិនបាន ។

ដានី៖ ប៉ុន្តែលោកអ៊ីសំរាន្តនៅពេទ្យហ្នឹងដល់ពេលណាមកនៅជាប់ជាមួយវរសេនាធំវិញ?

វ៉ែន៖ តាមពិតកំលាំងខ្ញុំភាគច្រើនឈ្នះភ្នំពេញហើយ គឺមានជាទិសបង្កបង្កើនផល ។

ដានី៖ ទិសបង្កបង្កើនផល?

វ៉ែន៖ បាទ! នៅភ្នំពេញតិចទេ តែនៅជាប់ខ្ញុំច្រើនគិតគូរពីរឿងធ្វើស្រែ ចំការ ។

ដានី៖ ទិសបង្កបង្កើនផលធ្វើស្រែ ធ្វើចំការនៅម្តុំណា?

វ៉ែន៖ ធ្វើម្តុំហ្នឹងផង ។

ដានី៖ នៅក្នុងទីក្រុងភ្នំពេញហ្នឹង?

វ៉ែន៖ អត់ទេ ធ្វើម្តុំខ្សាច់ពូនភ្នំ ។

ដានី៖ ម្តុំវត្តពូនភ្នំហ្នឹង?

វ៉ែន៖ បាទ!

ដានី៖ ហើយលោកអ៊ំនៅណា?

វ៉ែន៖ ខ្ញុំនៅហ្នឹង ។

ដានី: អត់ចូលទៅក្នុងទីក្រុងភ្នំពេញទេ?

វ៉ែន: ខ្ញុំចូលភ្លែតៗទេ ។

ដានី: នៅបានយូរទេលោកអ៊ំ?

វ៉ែន: ទេ ខ្ញុំនៅមិនបានយូរប៉ុន្មានទេ ដល់ពេលគេរៀបចំមករតនគិរី ខ្ញុំចូលទៅរៀបចំហើយខ្ញុំមកវិញ ដល់ថ្ងៃចេញបានខ្ញុំចេញ ។

ដានី: ចុះលោកអ៊ំពេលដែលកងទ័ពយើងចូលទៅប្រទាំងប្រទើសជាមួយប្រជាជន នៅពេញទីក្រុង

វ៉ែន: ដូចខ្ញុំបានទៅស្រាយបំភ្លឺហើយ គឺថាខ្ញុំភ្ជាប់មិនបានទេ ដល់ពេលឈ្នះភ្នំពេញហើយ គេប្រាប់ថាឈ្នះហើយ ខ្ញុំមកនៅកន្លែងហ្នឹងវិញ ឃើញប្រជាជនចេញ ។

ដានី: លោកអ៊ំមានប្រសាសន៍ថាទៅស្រាយបំភ្លឺនៅខាងសាលាក្ដី?

វ៉ែន: បាទ!

ដានី: អ៊ីចឹងលោកអ៊ំអត់ដឹងបានថាពេលដែលគេឈ្នះហើយ នៅទីក្រុងភ្នំពេញយ៉ាងម៉េចអត់ដឹងទេ

វ៉ែន: អត់ដឹងទេ ។

ដានី: ហើយលោកអ៊ំពេលហ្នឹងកងពល១៨គេចាប់ផ្ដើមប្ដូរឈ្មោះពីអង្គាល់ទៅ?

វ៉ែន: អត់ទេ ពេលឈ្នះភ្នំពេញអត់ទាន់ប្ដូរទេ ទាល់តែរៀបចំ តាមពិតកងពល១៨គ្រាន់តែជារូបភាពទេ មិនទាន់ប្រកាសជាផ្លូវការទេ ដល់ពេលឈ្នះទីក្រុងភ្នំពេញហើយបានប្រញាប់ចូលគ្នាទាំង៨១, ៨២, ៨៣, ៨៤ចូលគ្នាហើយ បានប្រកាសកងពល៨០១ ត្រូវទៅនៅរតនគិរី ហើយអង្គភាព៨១នៅសាលាក្រោង ហើយអង្គភាព៨៣នៅអូរតាម៉ោក ហើយអង្គភាព៨២នៅម្ដុំព្រំដែនលាវចាប់ពីផ្លូវ១៣ ទល់អូរតាវ៉ា ទន្លេសេសាន ហ្នឹងអង្គភាពខ្ញុំ ។

ដានី: អ៊ីចឹងអ៊ំចាំទេពេលដែលយើងចាប់ផ្ដើមប្រកាសឈ្មោះជាផ្លូវការ ជាឈ្មោះកងពល៨០១ គេប្រកាសនៅពេលណាទៅអ៊ំ?

វ៉ែន: ខ្ញុំចាំមិនបានទេ តែដាច់ភ្នំពេញរៀបចំទៅទន្លេសេសាន ។

ដានី: ដាច់បានយូរទេ លោកអ៊ំមានប្រសាសន៍ថាចូលទៅធ្វើស្រែនៅវត្តកន្លែងវត្ត?

វ៉ែន: គ្រាន់តែត្រៀមធ្វើតែអត់បានធ្វើទេ ។

ដានី: បានប្រហែលប៉ុន្មានខែដែលយើងនៅទីក្រុងភ្នំពេញ?

វ៉ែន: ខ្ញុំចាំមិនបានទេ ។

ដានី: ហើយពេលដែលប្រកាសហ្នឹងពីណាគេអ្នកប្រកាស ហើយអ្នកប្រកាសជាផ្លូវការថាកងពល១៨ហ្នឹងជាឈ្មោះផ្លូវការជាកងពល៨០១ ហើយត្រូវទៅការពារព្រំដែននៅរតនគិរីប្រកាសនៅកន្លែងណា ហើយពីណាអ្នកប្រកាស?

វ៉ែនៈ ប្រកាសនៅស្តាតហ្នឹងឯង ។

ដានីៈ ប្រកាសនៅស្តាតអូរឡាំពិក?

វ៉ែនៈ បាទ!

ដានីៈ ពីណាអ្នកមកប្រកាស?

វ៉ែនៈ ប៉ុល ពត, អៀង សារី ។

ដានីៈ តែ២នាក់ហ្នឹងទេ?

វ៉ែនៈ បាទ!

ដានីៈ តាសុន សេន, នួន ជា, វ៉ន វ៉េត, ខៀវ សំផន គាត់អត់ចូលរួម?

វ៉ែនៈ អត់ទេ ។

ដានីៈ មានតែ២ទេមកប្រកាសហ្នឹង?

វ៉ែនៈ បាទ!

ដានីៈ កាលហ្នឹងគេប្រកាសជាកងពល មានកងពលផ្សេងៗទៀតត្រូវប្រកាសជាមួយគ្នាតែមួយ ឬតែកងពលអ៊ី?

វ៉ែនៈ តែមួយទេ ប្រកាសតែមួយ តែប្រធានកងពលអត់ចូលរួម ក្តាប់មិនបាន មិនស្គាល់ តែក្នុងបញ្ជាការកងពល១៨ និងវរសេនាធំមួយៗមានមុខនៅហ្នឹង ហើយយុទ្ធជនទាំងអស់ស្តាប់ហើយប្រកាសហើយចប់ចេញដំណើរ ។

ដានីៈ ហើយអីចឹងប្រកាសឈ្មោះកងពលហើយ កាលហ្នឹងអ្នកដែលចូលរួមមានតែបញ្ជាកាកងពល ហើយនិងបញ្ជាការវរសេនាធំ?

វ៉ែនៈ បាទ!

ដានីៈ ដែលចូលរួមប្រកាស មានតាប៉ុល ពត និងអៀង សារី គាត់មកប្រកាស មានតែបញ្ជាការកងពល ហើយនិងបញ្ជាការវរសេនាធំទេដែលមានសិទ្ធិចូល?

វ៉ែនៈ មានវរសេនាតូចខ្លះ ។

ដានីៈ ហើយពេលគេដូរឈ្មោះកងពលឲ្យទៅជាកងពល៨០១ហ្នឹងហើយ តើឈ្មោះវរសេនាធំមានផ្លាស់ប្តូរ?

វ៉ែនៈ អត់ទេ អត់មានផ្លាស់ប្តូរ ។

ដានីៈ វរសេនាធំនៅ៨១, ៨២, ៨៣ តែ៣វរសេនាធំហ្នឹងទេ?

វ៉ែនៈ បាទ!

ដានីៈ ហើយបញ្ជាការកងពលនៅដដែល ឬមានការផ្លាស់ប្តូរដែរ?

| | |
|---|---|
| វ៉ែន៖ | អត់មានផ្លាស់ប្តូរទេ ។ |
| ដានី៖ | នៅតែសូ សារឿន(០៥) ហើយនិងតាសាន (០៦)? |
| វ៉ែន៖ | បាទ! |
| ដានី៖ | អ៊ំឈ្មោះតាសូ សារឿន គាត់ឈ្មោះ(០៥) គេហៅគាត់០៥ពីអង្គាល់? ហើយម៉េចបានហៅ០៥អីចឹង? |
| វ៉ែន៖ | តាមពិតលេខគេអូទេ ។ |
| ដានី៖ | លេខគេអូហ្នឹងគេហៅគាត់តាំងពីអង្កាល់? |
| វ៉ែន៖ | តាមខ្ញុំដឹងវៃចូលភ្នំពេញហើយទេហៅ០៥៧ ។ |
| ដានី៖ | ពេលវៃចូលភ្នំពេញហ្នឹង? |
| វ៉ែន៖ | បាទ! |
| ដានី៖ | ០៥៧លេខគេអូពេលវៃចូលភ្នំពេញ? |
| វ៉ែន៖ | បាទ! |
| ដានី៖ | ០៦ក៏អីចឹងដែរ? |
| វ៉ែន៖ | បាទ! |
| ដានី៖ | ហើយអ៊ំមានលេខគេអូលេខប៉ុន្មាន? ឈ្មោះជាលេខ? |
| វ៉ែន៖ | អត់មានឈ្មោះពិតប្រាកដទេ ។ |
| ដានី៖ | បើគាត់ឈ្មោះគាត់នៅហ្នឹងដដែល? |
| វ៉ែន៖ | បាទ! |
| ដានី៖ | ៨០១ប្រធានកងពលនៅសូ សារឿន ដដែល? |
| វ៉ែន៖ | បាទ! |
| ដានី៖ | ចុះអនុកងពល? |
| វ៉ែន៖ | តាសាន ហ្នឹងឯង ។ |
| ដានី៖ | តាសាន ហ្នឹងដដែល? |
| វ៉ែន៖ | បាទ! |
| ដានី៖ | តែពីរនាក់ហ្នឹងទេអត់មានដំឡើងថែមទៀតទេ? |
| វ៉ែន៖ | អត់មានទេ ។ |
| ដានី៖ | ហើយវរៈ៨១ មានការផ្លាស់ប្តូរអីដែលទៀតអត់? |
| វ៉ែន៖ | អត់ទេ ។ |

ដានី៖ តែនៅកែវ សារឿន ៨១ដដែល?

វ៉ែន៖ បាទ!

ដានី៖ ហើយ៨២ លោកអ៊ំដដែល? អ៊ុន វ៉ែន ។

វ៉ែន៖ បាទ!

ដានី៖ ហើយ៨៣នៅតែតាធិន, តាឡី ដដែល?

វ៉ែន៖ បាទ!

ដានី៖ អ៊ំចាំទេ កាលពេលអ៊ំទៅរតនគិរីយើងជិះអីទៅ? ជិះទៅផ្ទាល់ពីភ្នំពេញទៅដល់រតនគិរីតែម្តង ឬមានស្នាក់អីនៅណាខ្លះដែរ?

វ៉ែន៖ កាលខ្ញុំទៅជិះម៉ូតូទេ ។

ដានី៖ អ៊ំជិះម៉ូតូទៅ?

វ៉ែន៖ បាទ!

ដានី៖ ជិះម៉ូតូទៅយ៉ាងម៉េច? ពីភ្នំពេញមកត្រង់ណា? ហើយពីត្រង់ណាទៅណា?

វ៉ែន៖ ពីភ្នំពេញទៅដល់ក្រចេះ ចាក់សាំងក្រចេះទៅទៀត ។

ដានី៖ អីចឹងជិះម៉ូតូពីភ្នំពេញទៅក្រចេះ ហើយចាក់សាំងពីក្រចេះទៅណាទៀត?

វ៉ែន៖ ទៅស្ទឹងត្រែង ។

ដានី៖ ហើយសំរាកនៅណាខ្លះ? ពេលយើងជិះពីភ្នំពេញទៅក្រចេះ សំរាកនៅណាទៅពេលយប់?

វ៉ែន៖ យប់ត្រង់ណាដេកត្រង់ហ្នឹងឯងតាមព្រៃ ។

ដានី៖ ក្នុងព្រៃដេកម៉េចកើតទៅ?

វ៉ែន៖ អង្រឹង ។

ដានី៖ ហើយលោកអ៊ំជិះម៉ូតូម្នាក់ឯង?

វ៉ែន៖ កងជង ។

ដានី៖ តែលោកអ៊ំក្នុងបញ្ហាការកងពល វរសេនាធំយើងជិះម៉ូតូទាំងអស់គ្នា?

វ៉ែន៖ បាទ!

ដានី៖ កាលហ្នឹងតា០៥, ០៦ គាត់ជិះម៉ូតូដែរ?

វ៉ែន៖ ឡានរបស់គាត់ ។

ដានី៖ គាត់ជិះឡាន?

វ៉ែន៖ បាទ!

ដានី៖ ហើយអ៊ីជិះម៉ូតូជាមួយអ្នកណាខ្លះទៅ?

វ៉ែន៖ វរសេនាធំ, វរសេនាតូច អ្នកណាជិះកង់ចាំគ្នាទំរាំតែដល់ ជួនកាលអ្នកណាគ្រុនទៅដល់នោះ ហើយដាក់នោះមកយកនេះទៀត ។

ដានី៖ ហើយប៉ុន្មានថ្ងៃទៅបានអ៊ីទៅដល់រតនគិរី?

វ៉ែន៖ បើថាខ្ញុំយឺតណាស់ ចង់មួយខែ ។

ដានី៖ ចង់មួយខែបានទៅដល់?

វ៉ែន៖ បាទ!

ដានី៖ ម៉េចអ៊ីចឹងយើងជិះម៉ូតូម៉េចបានយឺត?

វ៉ែន៖ ចាំអ្នកគ្រុន ទៅដល់ឲ្យម៉ូតូគេមកយក ដល់ហើយបានទៅទៀត អ្នកណាគ្រុនឲ្យយកម៉ូតូមកទៀត ។

ដានី៖ ដល់ពេលយើងទៅដល់រតនគិរីយើងចាប់ផ្ដើមបែងចែកទីតាំង?

វ៉ែន៖ អត់ទេ ផែនការបែងចែកតាំងពីនេះ ។

ដានី៖ ផែនការបែងចែកតាំងពីណាទៅ?

វ៉ែន៖ បែងចែកតាំងពីភ្នំពេញទៅហើយ ។

ដានី៖ អ្នកដែលប្រកាសបែងចែកពីណាគេ?

វ៉ែន៖ ដូចនោះហើយ ជំរាបម៉ិញ ។

ដានី៖ តាប៉ុល ពត?

វ៉ែន៖ បាទ!

ដានី៖ តាប៉ុល ពត គាត់អ្នកបែងចែកតែម្ដង?

វ៉ែន៖ បាទ!

ដានី៖ ថាវរសេនាធំ៨១នៅត្រង់នេះ, ៨២នៅត្រង់នោះ និង៨៣នៅត្រង់នេះ!

វ៉ែន៖ គេបង្ហាញតាមចំណុចហើយយើងទៅតាមហ្នឹង ។ ឧទាហរណ៍វរសេនាធំខ្ញុំថាទៅស៊ីងត្រែងសួរគេទៅ សៀមបាងនៅណាសួរគេទៅ ។

ដានី៖ ចុះមន្ទីរកងពលនៅណាទៅ?

វ៉ែន៖ មន្ទីរកងពលនៅវ៉ឺនសៃ ។

ដានី៖ ដំបូងបំផុតទៅដល់វ៉ឺនសៃតែម្ដង?

វ៉ែន៖ បាទ!

ដានី៖ ហើយវរសេនាធំមួយៗទៅតាមទីតាំងរបស់យើងទៅ?

វ៉ែនៈ បាទ!

ដានីៈ ហើយវរសេនាធំរបស់លោកអ៊ំ៨២នៅសៀមបាង ទៅទល់នឹងព្រំដែនឡាវ?

វ៉ែនៈ បាទ!

ដានីៈ ហើយ នៅខាងកន្ទុយនាគប៉ែតប៉ុន្មាន?

វ៉ែនៈ នោះអាច៨៣, ៨១ ។

ដានីៈ ហើយអ៊ំទៅនៅខាងកងពលហ្នឹងនៅរហូតឬយ៉ាងម៉េច?

វ៉ែនៈ អត់ទេខ្ញុំនៅហ្នឹងមួយរយៈហើយខាងលើហៅមករៀបចំគ្រួសារនៅភ្នំពេញ ។

ដានីៈ ឆ្នាំណាអ៊ំត្រឡប់មកភ្នំពេញវិញ?

វ៉ែនៈ ខ្ទង់៧៧ ។

ដានីៈ អ៊ំទៅរតនគិរីឆ្នាំ៧៥ ។

វ៉ែនៈ ៧៦ ។

ដានីៈ ចុងឆ្នាំ៧៥ហើយ?

វ៉ែនៈ បាទ!

ដានីៈ ដល់ពេល៧៧ខែប៉ុន្មានទៅដែលអ៊ំត្រឡប់មកវិញហើយខាងលើហៅអ៊ំត្រឡប់មកវិញ?

វ៉ែនៈ ខ្ញុំអត់ចាំទេ ។

ដានីៈ ខែប្រាំង ឬខែវស្សា?

វ៉ែនៈ ខែវស្សា ។

ដានីៈ ឆ្នាំ៧៧ខាងលើពីណាគេដែលហៅអ៊ំត្រឡប់មកវិញ?

វ៉ែនៈ សុន សេន ហើយនិងប៉ុល ពត ។

ដានីៈ គាត់ហៅអ៊ំត្រឡប់មកនៅណាវិញទៅ?

វ៉ែនៈ ត្រឡប់មកភ្នំពេញសួរបញ្ជាក់រឿងគ្រួសារ ។

ដានីៈ អ៊ីចឹងអ៊ំរៀបគ្រួសារឆ្នាំ៧៧ហ្នឹង?

វ៉ែនៈ អត់ទេ មកនៅនេះហើយគាត់សួរលិច-កើត ហៅឲ្យមកមើលលិច-កើតអត់មានត្រូវក៏ទៅ រកទៀត រកទៀតមិនត្រូវទៀត រកទាល់តែត្រូវ ។

ដានីៈ រកទាល់ត្រូវ?

វ៉ែនៈ បាទ!

ដានីៈ អ៊ីចឹងគាត់ហៅអ៊ំមកអ៊ីចឹង គោលបំណងសំខាន់បំផុតចង់ឲ្យលោកអ៊ំរៀបគ្រួសារ?

វ៉ែនៈ បាទ!

ដានី៖ រៀបគ្រួសារដូចថាអ្នកដែលគាត់ឲ្យអ៊ំជ្រើសរើសហ្នឹងហៅពីណាមកខ្លះ?

វ៉ែន៖ មិនចាំទេ តាមពិតនារីតាមកងដឹកជញ្ជូន។

ដានី៖ កាលហ្នឹងអ៊ំអាយុប៉ុន្មានហើយបានគាត់ហៅឲ្យទៅរៀបគ្រួសារ?

វ៉ែន៖ មិនចាំទេ។

បូលី៖ ពេលហៅអត់ភ័យថាគេហៅមកធ្វើអីពេលហ្នឹង?

វ៉ែន៖ ខ្ញុំអត់មានរឿងអីថាត្រូវភ័យ។

បូលី៖ អ៊ំជិះអីមកពីរតនគិរីមកភ្នំពេញ?

វ៉ែន៖ បាទ?

បូលី៖ ជិះអីមកពេលហ្នឹង?

វ៉ែន៖ ឡាន។

បូលី៖ មិនមែនយន្តហោះទេ?

វ៉ែន៖ អត់ទេ។

បូលី៖ ប៉ុន្មាននាក់ដែរពេលដែលអ៊ំអញ្ជើញមកភ្នំពេញ?

វ៉ែន៖ អត់ទេ មកម្នាក់ឯងជាមួយកងពល។

បូលី៖ ៨០១ហ្នឹង?

វ៉ែន៖ បាទ! ប្រធានកងពល។

ដានី៖ ជាមួយតាសារឿន?

វ៉ែន៖ បាទ! មកជាមួយតាសារឿន, ជាមួយវរសេនាធំគ្រប់វរសេនាធំ មករៀនហើយ ឥឡូវរៀនចប់ហើយចង់រៀបគ្រួសារឲ្យខ្ញុំ ដល់អីចឹងពិនិត្យមើលទៅរកវាមិនត្រូវក៏គេអត់ត្រូវរ៉ូវគ្នា វរសេនាធំមួយៗគេចាំចង់រៀបការនៅជាមួយខ្ញុំដែរ ដល់ខ្ញុំមិនត្រូវចេះតែពន្យាគេទៅមុនទៅ។

បូលី៖ អីចឹងកាលដែលមកដំបូងបំណងបញ្ជូនឲ្យមករៀនទេតាមពិត?

វ៉ែន៖ រៀនចប់ហើយ ហ្នឹងត្រូវតាឡី មួយទេ។ តាឡី ត្រូវជាមួយឈ្មោះ សៀន។។

ដានី៖ តាឡី គាត់ទៅណាវិញ?

វ៉ែន៖ តាឡីគាត់ថ្ងៃហ្នឹងរៀនត្រូវគ្នា។

ដានី៖ គាត់រៀបគ្រួសារបានតាឡី មួយ!

វ៉ែន៖ បាទ! នៅតែខ្ញុំហ្នឹង។

បូលី៖ រៀនអីគេអ៊ំ រៀននៅភ្នំពេញ?

វ៉ែនៈ	រៀនទស្សនៈយើងឈ្នះហើយ យើងខំប្រយុទ្ធកសាងដោះស្រាយជីវភាពកងទ័ព ហើយខ្ញុំមានអី មានតែចោរព្រៃ ។ ពេលហ្នឹងវរសេនាធំមួយ សូម្បីតែវរសេនាតូចចុះស្រែទាំងអស់គ្នាអត់មានអ្នកនៅទំនេរបានទេ ព្រោះខ្លាចងាប់ បើមិនធ្វើម៉េច ។

បូលីៈ	អ្នកណាគេអ្នកបង្រៀនកាលហ្នឹង?

វ៉ែនៈ	មានតាពត អ្នកបង្រៀន ។

បូលីៈ	តាប៉ុល ពត មួយ ហើយមានពីណាទៀតទេក្រៅពីតាប៉ុល ពត?

វ៉ែនៈ	អត់ទេ ។

បូលីៈ	មើលទៅការបង្រៀនរបស់គាត់ មានអត្តចរិត លក្ខណៈកាយវិការយ៉ាងម៉េចតាប៉ុល ពត?

វ៉ែនៈ	អត់មានអត្តចរិតយ៉ាងម៉េចទេ ធ្វើម៉េចដោះស្រាយជីវភាពខ្លួនឯងបានហើយ វាសំរាលដល់ប្រជាជនហើយ យើងការពារប្រទេសក៏បាន កសាងប្រទេសក៏បាន ។

បូលីៈ	គាត់និយាយមួយឬគាត់និយាយញាប់តាប៉ុល ពត?

វ៉ែនៈ	និយាយមួយ ។

បូលីៈ	គាត់និយាយតែឯង ឬគាត់ផ្តល់ឱកាសឲ្យអ្នករៀនសិក្ខាកាមបានសួរនាំ?

វ៉ែនៈ	សួរដែរ អ្នកខ្លះគេសួរ តែខ្ញុំមិនដែលសួរទេ ឲ្យទៅខំធ្វើ គិតខំតែធ្វើ ។

បូលីៈ	គាត់បាននិយាយពីសភាពការណ៍ព្រំដែនខ្មាំងយួនទេពេលហ្នឹង?

វ៉ែនៈ	និយាយ ។

បូលីៈ	អ៊ំអាចចាំចំណុចណាដែលគាត់សង្កត់បានទេ? សង្កត់បញ្ជាក់របស់គាត់?

វ៉ែនៈ	ចាំត្រង់ថាភារកិច្ចរបស់វរសេនាធំ៨២គឺទទួលខុសត្រូវចាប់ពីផ្លូវជាតិលេខ៨ ទល់គ្នានឹងទន្លេសេកុង ការពារឲ្យបាន ធ្វើម៉េចកុំឲ្យខ្មាំងសត្រូវចូលបាន ។ ហើយខាងសាលាក្រោមមាន៨១ធ្វើម៉េចកុំឲ្យយួនចូលយកទឹកដីបាន ។

ដានីៈ	សាលាក្រហម?

វ៉ែនៈ	សាលាខម ។

ដានីៈ	សាលាខម នៅក្នុងស្រុក នៅកន្លែងណា?

វ៉ែនៈ	ហួសសៀមបាង ។

បូលីៈ	ម្តុំនេះសៀមបាង ក្បែរព្រំដែនឡាវ?

វ៉ែនៈ	បាទ! ហ្នឹងហើយ ។ ណាសាលាខម?

បូលីៈ	វាអត់មានបញ្ជាក់សាលាខម ហ្នឹងទេ តែនេះ៨២នៅម្តុំនេះ ស្រុកសៀមបាង ខេត្តស្ទឹងត្រែង?

វ៉ែន: បាទ!

បូលី: ជាប់ខេត្តអាគាពើរបស់ឡាវ នេះឡាវ ។ ខាងនេះ៨១ ។

វ៉ែន: អូរតាម៉ោក ។

បូលី: អត់ដឹងកន្លែងណា ដែនទីអត់បញ្ជាក់ វាបញ្ជាក់តែធំៗ ។

វ៉ែន: អាចម្តុំនេះ ។

បូលី: នេះព្រំដែនវៀតណាម ។

វ៉ែន: ហ្នឹងហើយ អាចម្តុំនេះ ។

បូលី: ហ្នឹងខាង៨១?

វ៉ែន: ពេលគេត្រូវវ៉ៃ វាបេះទៅ ចង់ដកខ្ញុំមកដាក់នេះវិញ ហ្នឹងមករៀនហើយកំពុងដាំបាយស៊ីយប់ ថាឥឡូវមិនកើតទេ ដកពួកបញ្ជាការ៨១ឲ្យមកនៅ៨២វិញ ។

បូលី: ប្តូរគ្នាបេះ?

វ៉ែន: បាទ! ដូរគ្នាបេះ ដល់ពេលបេះខ្ញុំតែម្តង គ្មានអ្នកណាខ្លាំងជាងអ្នកណាទេ អ្នកណានៅណានៅហ្នឹងទៅ ។

បូលី: ពីណាចង់ដកហ្នឹង? តាប៉ុល ពត?

វ៉ែន: អត់ទេ ០៥ បញ្ជាការកងពល ។ អីចឹងដក៨២ទៅនោះវិញ ៨២លាវមកគេដេញទៅផុតតែ៨១ យួនមកនៅដាំស្មោនៅហ្នឹងហើយ ឥឡូវយកបញ្ជាការ៨២មកដាក់នៅហ្នឹងវិញ ថាអត់ទេ កន្លែងណាក៏ដូចណា ដូចតែគ្នាទេ ។

ដានី: កាលហ្នឹងអ៊ំនៅ៨២ នៅខាងលាវ?

វ៉ែន: បាទ! លាវ ។

ដានី: ហើយគេចង់ដកអ៊ំទៅខាងនោះវិញ ព្រោះយួនចូល?

បូលី: យួនបុកខ្លាំងជាងលាវ?

វ៉ែន: ហ្នឹងហើយ ។

ដានី: ខាង៨២ ។

វ៉ែន: ព្រោះ៨៣ ហើយនិង៨១ជាប់គ្នា បើ៨៣នៅនេះ ៨១អាចនៅម្តុំនេះ ។

បូលី: ព្រំដែនវៀតណាមដូចគ្នា ។

វ៉ែន: បាទ!

ដានី: ព្រោះពួកនេះវាធ្វើការដល់កន្ទុយនាគ ។

បូលី: ៨៣នៅខាងកន្ទុយនាគ ។

ដានីៈ	អ៊ំនៅភ្នំពេញរយៈពេលប៉ុន្មានទៅ? គេប្រជុំអស់ហើយគេត្រឡប់មកវិញ ហើយតាឡី គាត់ត្រូវមុនអ៊ំ គាត់ត្រឡប់មកមុនដែរ?

វ៉ែនៈ	ខ្ញុំដល់ពេលនិយាយត្រឡប់មកវិញ ដល់ពេលតាឡី រៀបការហើយ មួយខែក្រោយមក បានខ្ញុំរៀប ហើយខ្ញុំទៅនៅបាងលុងវិញ គេដកខ្ញុំលែងឲ្យចូលអង្គភាពវិញហើយ ។

បូលីៈ	មកនៅបាងលុង ទីរួមខេត្តរតនគិរីវិញ?

វ៉ែនៈ	បាទ! ហ្នឹងហើយ លែងនៅបាងលុង ។

ដានីៈ	អ៊ំមកខាងរដ្ឋអំណាចវិញ?

វ៉ែនៈ	អត់ទេ ដូចខ្ញុំស្រាយបំភ្លឺថាពេលនោះមិនដឹងយ៉ាងម៉េចទេ មុនឃួនចូលមិនទាន់ចូលទេ គេដកខ្ញុំទៅនៅនោះ ការប្រាស្រ័យទាក់ទងអង្គភាពខ្ញុំ ទាក់ទងកងពល គ្មានអីទាំងអស់ ។

បូលីៈ	ទៅធ្វើអីវិញមកបាងលុង?

វ៉ែនៈ	ធ្វើផ្ទះមួយ ផ្ទះយើងធ្វើឫស្សីដូចជនជាតិ ធ្វើឫស្សីនៅម្នាក់ឯង ។

ដានីៈ	បានន័យអ៊ំមានខុសអីគេបញ្ឈរជើងអ៊ំ ឬយ៉ាងម៉េច?

វ៉ែនៈ	តាមខ្ញុំពិចារណាទេ តែខ្ញុំមិននិយាយទេ តែខ្ញុំដឹងថាបើមានបញ្ហាអីចឹងមានតែរឿងបញ្ហាអី ដល់ខ្ញុំស្រាវៗទៅ មានតែ កែវ សារឿន នេះឆ្លើយដាក់ខ្ញុំ ដល់អីចឹង សុន សេន និយាយប្រាប់ខ្ញុំថាមិត្តឯង មានគេឆ្លើយដាក់ហើយ គិតម៉េចសួរខ្ញុំអីចឹង សួរថាពីណាឆ្លើយ កែវ សារឿន ។ ខ្ញុំថាបើឆ្លើយដាក់ក៏ឆ្លើយទៅ តែអាហ្នឹងស្រេចតែលើពិចារណាទៅ ។

បូលីៈ	មានចំលើយសារភាព កែវ សារឿន ។

ដានីៈ	មាន ។

បូលីៈ	បានអានទេ?

ដានីៈ	អាន តែភ្លេចអស់ហើយ កាលហ្នឹងអត់ចាប់អារម្មណ៍អីផង ។

បូលីៈ	តាកែវ សារឿន មានចម្លើយសារភាពនៅទួលស្លែង ។

វ៉ែនៈ	បាទ!

បូលីៈ	អានទៅអាចប៉ះឈ្មោះអ៊ំ ឈ្មោះពីណានៅជុំវិញមួយគំនរ ។

វ៉ែនៈ	បាទ! ការពិតខ្ញុំនិងកែវ សារឿន ស្គាល់គ្នាតាំងពីយូរហើយ តែមិនដែលទាក់ទងគ្នា តែសម័យដូចខ្ញុំជិភពអស់លោកអីចឹង សូម្បីតែយើងឈ្នះហើយភារកិច្ចរបស់៨១, ៨២, ៨៣ ទៅនៅកន្លែងណា ពេលមកជួបគ្នារៀនសូត្រគ្មានដែលនិយាយជាមួយពីណាទេ ឧបមាថាចាប់ខ្ញុំហើយចេះតែឆ្លើយដាក់ ធ្វើព្រងើយៗរៀងខ្លួនទៅ ហ្នឹងអីចឹងឯង ។

ដានីៈ	អ៊ំមានធ្លាប់មកនៅខាងអគ្គសេនាធិការទេ?

វ៉ែន: អ៊ីចឹងបានខ្ញុំចង់បញ្ជាក់ថា ដូចថាខ្ញុំនៅក៏បាន ថាអត់ក៏បានដែរ ខ្ញុំមកមួយរយៈនេះដូចថាផ្ញើរខ្លួន រៀបគ្រួសារទេ ។

ដានី: បាទ?

វ៉ែន: ខ្ញុំមកនៅដូចថារៀបចំគ្រួសារដល់រកមិនទាន់បាន បេះតែហៅខ្ញុំមកបាយទឹក ។

បូលី: នៅសេនាធិការហ្នឹង?

វ៉ែន: ហ្នឹងហើយ ហើយខ្ញុំស្គាល់កងពលទៅដេកលេងហ្នឹង ថ្ងៃណាចង់ហូបបាយក៏ហូបបាយ ។

ដានី: អ៊ំនៅអគ្គសេនាធិការហ្នឹងក្រៅពីសុន សេន ពីណាខ្លះទៀតដែលធ្វើការនៅអគ្គសេនាធិការកាលជំនាន់អ៊ំនៅហ្នឹង?

វ៉ែន: ខ្ញុំអត់ទេ ខ្ញុំអត់ដែលឃើញមានពីណាទេ មានតែសុន សេន មួយ ។

ដានី: ចុះនៅកន្លែងការិយាល័យមានដូចជា ៦២, ៦៣, ៦៤, ៦៥, ៦៦?

វ៉ែន: ទេ កាលនោះខ្ញុំឃើញមានតាសោម, តាណាត ។

ដានី: តាសោម, តាណាត ពីណាទៀតដែលអ៊ំ?

វ៉ែន: ខ្ញុំដឹងតែប៉ុណ្ណឹង ។

ដានី: អ៊ីចឹងអ៊ំទៅភ្នំពេញ ទៅអគ្គសេនាធិការហ្នឹងដូចអ៊ំមានប្រសាសន៍ហ្នឹងថាប្រជុំហើយរើសគ្រួសារ ទៅបាយទឹក?

វ៉ែន: បាទ! ខ្ញុំមិនបានទៅចូលរួមប្រជុំទេ ។

ដានី: លោកអ៊ំពេលដែលអញ្ជើញត្រឡប់ទៅកងពលវិញ ទៅរតនគិរីវិញឆ្នាំណាទៅ?

វ៉ែន: ខ្ញុំទៅនៅបានប្រហែល១ខែយួនបាញ់ ។

បូលី: ទៅនៅរតនគិរីវិញបាន១ខែ យួនវ៉ៃចូល?

វ៉ែន: បាទ!

ដានី: អ៊ីចឹងតាំងពី៧៧អ៊ំនៅភ្នំពេញរហូត?

វ៉ែន: បាទ! មិននេះទេ អាចពាក់កណ្ដាល៧៧ខ្ញុំទៅនោះវិញ ។

ដានី: មកនៅណាវិញ?

វ៉ែន: ទៅនៅបាងលុងវិញហើយ ។

ដានី: ពាក់កណ្ដាល៧៧មកបាងលុងវិញ ដែលអ៊ំមានប្រសាសន៍ថាគេឲ្យអ៊ំនៅផ្ទះមួយតែឯង?

វ៉ែន: បាទ!

ដានី: នៅបាងលុងដែលថាអ៊ំពិចារណាមិញ ប្រហែលជាគេឆ្លើយដាក់ ដូចថា កែវ សារឿន គាត់ឆ្លើយដាក់នៅបាងលុង នៅរយៈពេលប៉ុន្មានទៅ?

វ៉ែនៈ ទេ ខ្ញុំមិនចាំទេ តែពេលខ្លីណាស់ ។ ចាំមើលខ្ញុំនិយាយដល់ពេលខ្ញុំទៅដល់ហើយ រូបភាពពីនេះទៅ សុន សេន ប្រាប់ខ្ញុំ ឥឡូវទៅនៅអគ្គភាពវិញ ស្អែកនេះយន្តហោះជូនដំណើរទៅ ហើយទៅជាមួយស៊ុន ដល់ពេលខ្ញុំទៅដល់ចុះនៅវ៉ើនសៃ ម៉ូតូគេមិនជូនទៅសៀមបាង គេឱបទៅបាងលុងវិញ តាំងពីខ្ញុំនៅបាងលុងរហូតខ្ញុំមិនដែលទាក់ទងកងពល ខ្ញុំមិនដែលទាក់ទងអគ្គភាពខ្ញុំបានទេ វរសេនាធំផ្សេងៗបាន អត់ទេ ។ ដូច្នេះអង្គរខ្ញុំរកដោះស្រាយប្រជាជនដែលធ្លាប់ស្គាល់ខ្ញុំអី គាត់ឲ្យអង្ករ ឲ្យមាន់ ឲ្យម្ហូបខ្លះហើយ ហើយបានមួយរយៈមកចាប់ផ្ដើមសរសេរសំបុត្រមកមួយ ០៥យកទៅឲ្យខ្ញុំថាខាងលើហៅមិត្តទៅវិញ ។ យកឯកសារហ្នឹងមក សារទូរលេខយកមកអានឲ្យខ្ញុំមើល ឥឡូវមិត្តរៀបចំចេញដំណើរទៅ ខ្ញុំក៏រៀបចំចេញដំណើរ ហើយខ្ញុំពិចារណាថាបើខ្ញុំទៅលើកនេះ ច្បាស់ជាចប់ហើយ មកដល់ស៊ឹងត្រែងមិនបាច់យកអ្នកណាមកទេ មកតែម្នាក់ឯងបានហើយ កប៉ាល់ហោះទៅយក ខ្ញុំថាអីចឹងចប់ហើយ ចេញដំណើរមកក្រោយពីបែក០៥ ក៏ចេញវឹងមកពាក់កណ្ដាលផ្លូវឃើញនីរសារគាត់បើកឡានមក គេមកថាឲ្យចាំសិនមានសំបុត្រជូន ខ្ញុំមកដល់កូនម៉ុំហុចសំបុត្រថាឲ្យមិត្តត្រឡប់វិញប្រញាប់ សភាពការណ៍អត់ស្រួលទេ យួនវ៉ៃចូលគ្រប់កន្លែង អីចឹងខ្ញុំត្រឡប់ទៅវិញ ទៅដល់គាត់ត្រឡប់ទៅសាលាខមបាត់ហើយ សួរខ្ញុំនៅណា ថាខ្ញុំដល់កន្លែងផ្ទះខ្ញុំហើយទៅដល់មួយសន្ទុះគាត់មកដល់ គាត់ណែនាំថាឥឡូវមិត្តមិនបាច់ទៅទេ យួនវ៉ៃចូលគ្រប់កន្លែង ឥឡូវភារកិច្ចរបស់មិត្តឯងខាងលើណែនាំមកថាឲ្យទទួលនៅកងពល៨០១នេះឯសំរាប់ខ្ញុំវិញខ្ញុំទៅនៅវ៉ើនសៃវិញ ដើម្បីរៀបចំយកគ្រាប់រំសេវលាក់ទុក ។

ដានីៈ អ៊ំមានប្រសាសន៍ហ្នឹង ខែណា ឆ្នាំណា?

វ៉ែនៈ យួនវ៉ៃហើយ ។

ដានីៈ ចុង៧៨ ឬយ៉ាងម៉េច ពេលដែលអ៊ំមានប្រសាសន៍?

វ៉ែនៈ យួនវ៉ៃហើយ កប៉ាល់ហោះពីលើ ពីក្រោមផង ហើយខ្ញុំបើកឡានទៅដល់បរកែវ រថក្រោះគ្រោងគ្រាតទៅដល់ហ្នឹង ចាប់ផ្ដើមរត់ចូលព្រៃ វង្វេងវង្វាំង ទប់ណាកងទ័ពទៅអស់ហើយខ្ញុំដល់ដាច់ពីគេមួយរយៈហើយគ្មានពីណាស្ដាប់ បើនៅអគ្គភាព៨២គេស្គាល់ ដល់អគ្គភាព៨១, ៨៣ គេអត់សូវស្គាល់ខ្ញុំ ប្រាប់ទៅលិចទៅកើត ។

ដានីៈ ៨៣ពីណាវិញដល់ពេលហ្នឹង?

វ៉ែនៈ ៨៣រត់ទៅព្រៃអស់ហើយ ។

ដានីៈ ពីណាប្រធាន៨៣កាលនោះ?

វ៉ែនៈ នៅតាឡី, តាធិនដែរ ដល់ពេលហ្នឹងដាច់ដោចគ្នាអស់ហើយ នៅតែខ្ញុំម្នាក់ឯងចេះតែទៅ ហើយ បាន២នាក់កូនក្មេងមួយគ្រាន់ដាំបាយស៊ី យូរៗទៅឃើញ១-២នាក់ចេះតែបបួលៗ បានហៅខ្សឹប ។

ដានីៈ អ៊ំខ្ញុំចង់បញ្ជាក់បន្តិច មិញពេលដែលពាក់កណ្តាលឆ្នាំ៧៥ អ៊ំត្រឡប់ទៅបាងលុង ដូចជាបញ្ឈរជើងអ៊ំដែរ កាលហ្នឹងនៅបាងលុងរយៈពេលប៉ុន្មានទៅ?

វ៉ែនៈ ខ្ញុំមិនចាំទេ ។

ដានីៈ យូរដែរ? រាប់ខែបក៏ប៉ុន្មាន?

វ៉ែនៈ អាច២ខែផ្ងាយ ។

ដានីៈ ចេញពី២ខែហ្នឹងអ៊ំទៅណាវិញ?

វ៉ែនៈ ចេញពី២ខែហ្នឹងយួនវ៉ៃចូល ។

ដានីៈ អីចឹងមិនមែន៧៧ទេ?

វ៉ែនៈ មិនដឹងចិតប៉ុន្មានទេ ។

ដានីៈ អាច៧៨ ។ អីចឹងអ៊ំនៅភ្នំពេញបានយូរដែរ?

វ៉ែនៈ អត់ទេ ខ្ញុំទៅមកៗ ។

ដានីៈ អាចប្រទ្បាំថ្ងៃខែ ។ កាលហ្នឹងលោកអ៊ំមានទៅកាន់ខាងនៅខាងភូមិភាគដែលអត់?

វ៉ែនៈ អត់ទេ អត់មានទេ ។

ដានីៈ ខាងតំបន់?

វ៉ែនៈ អត់ ។

ដានីៈ តាធិន គាត់ទៅខាងតំបន់ តែអ៊ំអត់មានទៅខាងតំបន់?

វ៉ែនៈ ធិន មកដល់នេះហើយបានឡប់ទៅវិញទេ ។

ដានីៈ មកដល់រតនគិរី?

វ៉ែនៈ អត់ទេ មកដល់នេះហើយ ។

បូលីៈ ១០០១ហើយ ។

វ៉ែនៈ បាទ! ហ្នឹងតាមខ្ញុំដឹង មកជុំគ្នា ឥឡូវមានបងប្អូនខាងជនជាតិ មានធិន ទៅទទួល ។

ដានីៈ លោកអ៊ំមានប្រសាសន៍មិញថាគេមានសំបុត្រហៅលោកអ៊ំទៅភ្នំពេញប្រញាប់ កាលហ្នឹងចុងឆ្នាំ៧៨ទេ?

វ៉ែនៈ មុនយួនចូល ។

ដានីៈ មុនយួនតែតិចទេ?

វ៉ែន៖ បាទ!

ដានី៖ ពេលដែលលោកអ៊ុំធ្វើដំណើរតាមម៉ូតូមកដល់កូនមុំ សំបុត្រពីតា០៥ហៅឲ្យអ៊ុំទៅវិញ?

វ៉ែន៖ បាទ! សំបុត្រពីលើទៅ ។

ដានី៖ សំបុត្រពីភ្នំពេញទៅ?

វ៉ែន៖ បាទ!

ដានី៖ ពីតាសុន សេន ឬតាប៉ុល ពត?

វ៉ែន៖ ទេ មិនដឹងពីណាទេ ដឹងតែខាងលើ សំបុត្រពីលើ ។

ដានី៖ សំបុត្រពីលើមកតា០៥ ឲ្យតា០៥ប្រាប់អ៊ុំថាមិនបាច់ទៅភ្នំពេញទេ ឲ្យត្រឡប់មកកងពលវិញ?

វ៉ែន៖ បាទ! ឲ្យជួយការងារ ។

ដានី៖ ចាប់ពីពេលហ្នឹងមកអ៊ុំទទួលជាបញ្ជាការកងពល៨០១ ឬយ៉ាងម៉េច?

វ៉ែន៖ ចាប់ពីណា?

ដានី៖ ពេលដែលគេឲ្យអ៊ុំត្រឡប់ទៅវិញ ពេលអ៊ុំមកដល់តាមផ្លូវខាងលើប្រាប់ថាមិនបាច់ទៅវិញ មកជួយការងារ៨០១វិញ?

វ៉ែន៖ ខ្ញុំសុំជំរាបថាខ្ញុំមិនចាំថ្ងៃទេ តែក្រោយពេលឲ្យខ្ញុំទទួលខុសត្រូវកំលាំងខាងមុខ ក្នុងកងពល៨០១នេះ ហើយ០៥, ០៦នេះ គេរៀបចំខាងក្រោយ គេរៀបចំទុកដាក់គ្រាប់រំសេវ តែតាមពិតគេរៀបចំអីវ៉ាដល់អស់ហើយ ដូច្នេះគេគេចទៅភ្នំកាពឹកទាំងអស់ ។

ដានី៖ ០៥, ០៦ គេច?

វ៉ែន៖ ហ្នឹងហើយ ទៅភ្នំកាពឹកទាំងអស់ ហើយកំលាំងភាគច្រើន វរសេនាធំគេហៅទៅហ្នឹងឯង ហើយខ្ញុំមានតេអូ នៅតែម្តុំបាងលុងហ្នឹងត្រឡប់ត្រឡិន ដកជំឡូងប្រជាជនហូប ទំរាំទាក់ទង បានគេហៅខ្ញុំទៅ ហៅខ្ញុំបានប្រហែលកន្លះខែ រៀបចំដំឡូងហាលឡើងលើភ្នំ ។

ដានី៖ ឆ្នាំណាដែលអ៊ុំចេញពីមណ្ឌលគិរីឡើងមកភ្នំបាន ឆ្នាំណាទៅ?

វ៉ែន៖ មិនចាំទេ ។

បូលី៖ ឆ្នាំប្រហែលលំបាកចាំ ពេលដែលវៀតណាមវ៉ៃចូលមកចុង៧៨ ខែមករា ៧៩ហ្នឹង អ៊ុំរត់ឡើងភ្នំក្វាម?

វ៉ែន៖ អត់ទេ ។

បូលី៖ រត់ក្នុងព្រៃសិន?

វ៉ែន៖ បាទ! នៅក្នុងព្រៃរហូត អត់ទាំងខោ អត់ទាំងអាវរយ៉េរយ៉ៃ ។

ដានី: កងទ័ពដែលនៅជាប់ជាមួយអ៊ំប្រហែលប៉ុន្មានទៅ?

វ៉ែន: ខ្ញុំទៅឃើញ១-២នាក់គេចេះតែតាម ឲ្យជាប់ខ្ញុំជាកង ១០-២០នាក់មកដឹបូងអត់តែម្ដង អត់មានទេ ទៅណាគេចេះឲ្យបាយទឹក រកកន្លែងជ្រក រកដំឡូង រកម្ហូបស៊ី នៅជាមួយគ្នាទៅ យូរៗបានច្រើនៗ ដល់គេដឹងដំណឹងគេស្រាវជ្រាវទៅហៅខ្ញុំទៅជួប ដល់ហៅខ្ញុំទៅជួបឲ្យរៀបស្បៀងអាហារឡើងភ្នំៗ

ដានី: ពីណាស្រាវជ្រាវហៅអ៊ំទៅជួប?

វ៉ែន: ០៥, ០៦ហ្នឹងៗ

ដានី: អ៊ំទៅជួបនៅណាទៅ?

វ៉ែន: នៅភ្នំការពឹកៗ

ដានី: នៅភ្នំរំពឹក?

វ៉ែន: បាទ!

ដានី: ក្នុងស្រុកអីគេ?

វ៉ែន: ជិតកន្ទុយនាគហ្នឹងឯងៗ

បូលី: អ៊ំរស់នៅម្ដុំណាពេលដែលអត់ទាន់ឡើងភ្នំ ពេលដែលវ៉ៃវៀតណាមចូល?

វ៉ែន: ខ្ញុំនៅម្ដុំបាងលុង ជិតសាលាដាក់មួយជួរហ្នឹង ព្រោះនៅម្ដុំហ្នឹងមានដំឡូងហូបៗ

ដានី: តែយួនអត់រកអ៊ំឃើញទេ?

វ៉ែន: រកអី៤-៥នាក់ នៅនេះដកដំឡូង ដុតដំឡូងនោះ ទៅដេកនោះៗ

បូលី: ក្នុងព្រៃ ឬក៏ក្នុងភូមិ?

វ៉ែន: ក្នុងព្រៃៗ

បូលី: ហើយសំរាន្តយប់ឡើង សំរាន្តយ៉ាងម៉េចទៅក្នុងព្រៃ?

វ៉ែន: អង្រឹងៗ

បូលី: ចងអង្រឹងដើមឈើទៅ?

វ៉ែន: បាទ!

ដានី: អីចឹងដូចអ៊ំធ្លាប់តែម្ដងគេងលើអង្រឹង?

វ៉ែន: បាទ!

ដានី: អត់មានបញ្ហាអីទេ?

វ៉ែន: អត់អីទេៗ

ដានី: មូសអី? ឈឺស្កាត់គ្រុនចាញ់?

វ៉ែនៈ អត់សូវអីទេ ។

បូលីៈ រយៈពេលប៉ុន្មានខែ តាមអីស្មានលេង១មើល បានតា០៥ទាក់ទងមក?

វ៉ែនៈ តាំងពីចុកចាកហ្នឹងទល់គ្នានឹង ហៅបានជិរាបគ្នាប្រហែល១០ថ្ងៃ ឡើងភ្នំ ដល់ឡើងភ្នំទៅជួប គេ គេមកមុនបាត់ ។

បូលីៈ គេមកយ៉ាងម៉េច?

វ៉ែនៈ គេមកមុនបាត់មក គេឡើងនោះ ខ្ញុំនៅគ្នា៦នាក់ទេ ឆ្លងទន្លេសេសានមក ឲ្យម្នាក់មកស៊ើប សន្យាជួបគ្នាត្រើយខាងនោះកំណត់កន្លែងហើយ ដល់គេគេចពីនោះយួននៅកន្លែងហ្នឹង គេ គេចបាត់ទៅ ដល់ម៉ោង៥ខ្ញុំឡើងមក ឃើញចងអង្រឹងព្រាត ។ អីយ៉ា ពួកហ្នឹងអង្រឹងស្អាត ៗម្ល៉េះ ម៉ោង៥ជិតភ្លឺ ទៅឈ្លបមើលដូចមិនមែនខ្មាំងទេ ហើយមើលក្រោមគេកាត់ឈើ ធ្វើបន្ទុងដាក់ស្បែកជើងប៉ាតា យួនហើយតាមមើល ចាប់ផ្ដើមលួចកាំភ្លើងពួកខ្ញុំ៤នាក់ទេ លួចកាំភ្លើងបានអាការម្នាក់មួយដើម គេនៅចំងាយនោះ ដល់ថាយួន គេភ័យគេងាកចេះ មកប៉ះឆ្នាំងបាយក្រូង យួនផ្អើលទៅ។ ចេញផុតប្រហែលផ្ទះនោះ លឺម៉ាត់យួនចេចចាច។ ដឹងថាបាត់កាំភ្លើងហើយបាញ់កាំភ្លើងលឺទុងតាំង១ ពួកខ្ញុំស៊ើបចាប់ផ្ដើមរ៉ៃគ្នា ១-២នាក់ ហើយយួនបាញ់ក្ដុងក្ដាំងណាស់ ទៅដល់បានប្រហែលពីនេះទៅជិតជើងភ្នំបានជួបគេ ជួបតា ០៥ ថាយួនរ៉ៃណាយប់មិញរ៉ៃពួកខ្ញុំហ្នឹងហើយ យកបានកាំភ្លើង អាការមួយដើម ។ គ្នា ចាំឯងយូរ ចាំអីអត់ចាំដង ។

បូលីៈ អ៊ំទៅជួបតា០៥ពេលហ្នឹងអាចស្មានបានទេ ប្រហែលជា៧៩ ឬដើម៨០?

ដានីៈ ដូចថាអ៊ំចេញរត់ចូលព្រៃហ្នឹង ប្រហែលជាប៉ុន្មានខែហើយ?

វ៉ែនៈ អាចចុង៧៨ ។

ដានីៈ បាទ?

វ៉ែនៈ អាចចុង៧៨ ជិតដាច់ ។

ដានីៈ ៧៩?

វ៉ែនៈ អាចចុង៧៨ ៧៩ ។

បូលីៈ អាចចុង៧៩ ព្រោះយួនវ៉ៃចូលមកដើម៧៩ហើយ ខែមករា ៧៩ ។ ដល់រត់ឡើងទៅហ្នឹង តា០៥ គាត់អ្នកនាំផ្លូវឬយ៉ាងម៉េច?

វ៉ែនៈ អត់ទេ គាត់នៅលើភ្នំដែរ មានកំលាំងគេប្រចាំការ នៅម្ដុំស្រែលាវ ស្រែក្រពើរនេះ គេនៅប្រចាំហ្នឹងមួយក្រុម១ ។

បូលីៈ បណ្ដាក់គ្នាដូចខ្សែអីចឹង?

វ៉ែនៈ គេបណ្ដាក់គ្នាតាមមាត់ទន្លេ ។

បូលីៈ ដល់កំលាំងយើងចូលទៅ គឺថាក្រុមមួយៗគេចន្លុលទិសទៅ គេនាំទៅ ។

វ៉ែនៈ គេនាំទៅ ។

បូលីៈ គេនាំទៅទៀត?

វ៉ែនៈ នាំទៅ ។

បូលីៈ គេឲ្យកំលាំងម្នាក់នាំទៅអីចឹង?

វ៉ែនៈ បាទ! ដល់កន្លែងគេមានមីហូបឆ្អែត ។

បូលីៈ កំលាំងហ្នឹងនាំរហូតដល់លើភ្នំ១០០១តែម្ដង?

វ៉ែនៈ បាទ!

បូលីៈ ទៅដល់លើភ្នំ១០០១យ៉ាងម៉េចទៅ គេចាត់តាំងយ៉ាងម៉េចទៀតទៅពេលទៅដល់ហ្នឹងដំបូងបំផុត? គេឲ្យសំរាកសិន ឬចាត់តាំងភ្លាម?

វ៉ែនៈ អត់ចាត់តាំងភ្លាមទេ សំរាក ។

បូលីៈ សំរាកបានរយៈពេលប៉ុន្មានដែរនៅលើហ្នឹង?

វ៉ែនៈ សំរាកបានមួយខែជាងអីទៅ ។

បូលីៈ ម៉េចក៏គេឲ្យអ៊ីសំរាកពេលហ្នឹង? ម៉េចក៏គេមិនចាត់តាំងភ្លាមៗ?

វ៉ែនៈ យើងហត់អស់កំលាំង ។

បូលីៈ គេបំប៉នយើងឲ្យមានសុខភាពសិន?

វ៉ែនៈ បាទ!

បូលីៈ ការរស់នៅលើភ្នំ១០០១ហ្នឹងអ៊ំនៅម៉ុំណា? ម៉ុំកងពល៨០១ដដែល ឬយ៉ាងម៉េច?

វ៉ែនៈ តាមពិតខ្ញុំនៅក្នុងកំឡុងកងពល៨០១ តែក្នុងកងពល៨០១ហ្នឹងមានសុន សេន គាត់អ្នកទទួលខុសត្រូវ ។

បូលីៈ សុន សេន គាត់ទទួលខុសត្រូវរួម?

វ៉ែនៈ បាទ!

បូលីៈ នៅលើភ្នំ១០០១ហ្នឹង?

វ៉ែនៈ មកខាង១០០៣មានតាម៉ុក, ១០០១ប៉ុន្មានកងពលគឺសុន សេន ។

បូលីៈ នៅលើភ្នំ១០០១ មានប៉ុន្មានកងពលទៅអ៊ំបើយើងរាប់ទៅ?

វ៉ែនៈ ច្រើនណាស់ ។

បូលីៈ ៨០១មួយ ។

វ៉ែនៈ ៨០១, ១០៥ ។

បូលីៈ មានអីទៀតអ៊ំក្រៅពីហ្នឹង? ខ្ញុំកត់បាន៤ៈ ៨០១, ៤១៧ នៅ១០០១ដែរ?

វ៉ែនៈ បាទ!

បូលីៈ ៩២០, ១០៥ ។ ៤កងពលនៅ១០០១ មានកងពលអីទៀតទេ ក្រៅពី៤កងពលហ្នឹង?

វ៉ែនៈ អត់ទេ មានតែប៉ុណ្ណឹង ។

បូលីៈ ៤កងពលហ្នឹង?

វ៉ែនៈ បាទ!

បូលីៈ តែកងពលមួយៗ ការបោះទីតាំងរស់នៅរបស់កងទ័ព និងគ្រួសារកងទ័ព គេបោះតាមកងពលគេ ឬយើងនៅប្រឡូកគ្នាពេញហ្នឹង?

វ៉ែនៈ អត់ទេ បោះតាមកងពលគេ ។

បូលីៈ កងពល៨០១យើងនៅមួយដុំចេះទៅ?

វ៉ែនៈ បាទ!

បូលីៈ ៩២០នៅមុំចេះទៅ?

វ៉ែនៈ បាទ!

បូលីៈ គ្រាន់តែចន្លោះពីកងពលមួយៗទៅកងពលមួយមិនឆ្ងាយពីគ្នាប៉ុន្មានទេ ឬឆ្ងាយ?

វ៉ែនៈ មិនឆ្ងាយទេ ។

បូលីៈ មិនឆ្ងាយពីគ្នាប៉ុន្មានទេ?

វ៉ែនៈ បាទ!

បូលីៈ អីចឹងអ៊ំនៅក្នុងបុករបស់កងពល៨០១ពេលហ្នឹង?

វ៉ែនៈ បាទ!

បូលីៈ ពេលហ្នឹងអ៊ំរត់ទៅទាំងគ្រួសារ ឬយ៉ាងម៉េច?

វ៉ែនៈ អត់ទេ ។

បូលីៈ ពេលណាបានជួបអ៊ំស្រីវិញ?

វ៉ែនៈ គ្រួសារខ្ញុំនេះទើបតែរៀបទេ មុនមិនដឹងនៅណាទេ បែកគ្នាតាំងពីយួនវ៉ៃមក ។

បូលីៈ បែកគ្នាតាំងពីយួនវ៉ៃចូលមកបែកគ្នារហូត?

វ៉ែនៈ បែករហូត ។

បូលីៈ មានតែដឹងដំណឹងទេក្រោយមក?

វ៉ែនៈ អត់ទេ ។

បូលីៈ	រហូតទល់សព្វថ្ងៃនេះ?

វ៉ែនៈ	បាទ!

បូលីៈ	បន្ទាប់មកក្រោយពីសំរាកបានមួយខែគេរៀបចំកំលាំងយ៉ាងម៉េចទៀត? ៨០១គេបំបែកជា៨០២ឬយ៉ាងម៉េច?

វ៉ែនៈ	៨០១ហ្នឹងខ្ញុំនិយាយតែក្នុងវង្វង់៨០១ទេ ក្រៅពីហ្នឹងខ្ញុំភ្លាប់មិនបានទេ ប៉ុន្តែក្រោយមករៀបចំកងពល៨០១មានហើយ ដល់អីចឹងខ្ញុំនេះគេដាក់៦០៧ៗ

បូលីៈ	៦០៧ហ្នឹងបំបែកចេញពី៨០១?

វ៉ែនៈ	បាទ! ៨០១ៗ

បូលីៈ	បំបែកពេលដែលអ៊ំទៅដល់លើភ្នំក្វាម?

វ៉ែនៈ	អត់ទេ បំបែកពេលរៀបចំចុះៗ

បូលីៈ	រៀបចំចុះមកខាងក្នុង?

វ៉ែនៈ	បាទ! ខាងក្នុងៗ

បូលីៈ	៦០៧ទីតាំងនៅ១០០១ ឬនៅ១០០៣?

វ៉ែនៈ	១០០១ៗ

ដានីៈ	អ៊ំចាំឆ្នាំទេ? ដែលគេបំបែកកងពល?

វ៉ែនៈ	អត់ចាំទេៗ

ដានីៈ	អ៊ំជាមួយតាញ៉ាន់?

វ៉ែនៈ	បាទ!

ដានីៈ	តាញ៉ាន់ នៅជាកងពល៦០៧ហ្នឹង?

វ៉ែនៈ	បាទ!

បូលីៈ	អីចឹងមិនមែនបំបែក៨០២ទេ?

វ៉ែនៈ	អត់ទេ ៨០១ទេៗ

បូលីៈ	ចុះ៨០២កើតពេលណា?

វ៉ែនៈ	ចាំមើលត្រង់ហ្នឹងវាក្រឡិកក្រឡុកច្រើនណាស់ៗ ៨០១តាមពិតដើមកំណើតរបស់វាមានតា០៥, ០៦ ដល់៨០២ហើយបានគេរៀបចំមួយកង ហៅថាកង៨០០ៗ

បូលីៈ	ពីណាគេមេពេលហ្នឹង?

វ៉ែនៈ	៨០០មានធិន ហ្នឹងឯងៗ

បូលីៈ	តាធិន, តាភាព?

វ៉ែនៈ បាទ!

បូលីៈ ទីតាំងរបស់៨០០នេះនៅលើភ្នំ១០០១ដែរ?

វ៉ែនៈ បាទ! ១០០១ដែរ។

បូលីៈ ដែលចេញមកពី៨០០១នេះ។

វ៉ែនៈ បាទ!

បូលីៈ ដល់ក្រោយមកបង្កើតមួយកងទៀត ៦០៧?

វ៉ែនៈ បាទ!

បូលីៈ របស់អ៊ំ?

វ៉ែនៈ បាទ!

បូលីៈ របស់អ៊ំនិងតាញ៉ាន់។ បន្ទាប់មកទៀតយ៉ាងម៉េចអ៊ំ?

វ៉ែនៈ បន្ទាប់មកទៀតក្រោយពីរៀបចំខ្ញុំ ហើយនិងតាញ៉ាន់ នេះហើយ ខ្ញុំទទួលប្រធានកងពល ដល់ទៅធ្វើការមួយរយៈកន្លែងណាដែលលំបាកឲ្យខ្ញុំទៅកន្លែងនោះ។ ឧទាហរណ៍នៅម្តុំនៅពើក និងរវៀង ដែលឃើញឡានចូលមិនបាន ត្រូវទាក់ទងប្រជាជនមិនបានឲ្យខ្ញុំទៅកន្លែងនោះ៦០៧។ ដល់ពេល៦០៧នេះខ្ញុំធ្វើកន្លែងណាគឺងតែងធ្វើបានស្រួលហើយ បានសុនសេន គេឲ្យខ្ញុំទៅនៅលើវិញ គេដកប្អូនថ្លៃទទួល៦០៧នេះវិញ។

ដានីៈ ដកតាឆន មកវិញ?

វ៉ែនៈ ឲ្យតាឆន មកនេះវិញ។

ដានីៈ តាឆន នេះមុនដំបូងគាត់នៅ៨០២?

វ៉ែនៈ ៨០២។

បូលីៈ អីចឹងដូចជាការផ្លាស់ប្តូរគ្នា?

វ៉ែនៈ បាទ!

ដានីៈ ដកតាឆន ឲ្យមកកាន់៦០៧ អ៊ំទៅណាវិញ?

វ៉ែនៈ ខ្ញុំនៅលើភ្នំ។

ដានីៈ លើភ្នំទទួលអីវិញ?

វ៉ែនៈ លើភ្នំទទួលតាមព្រំដែន។

ដានីៈ ទទួលប្រជាជនវិញ?

វ៉ែនៈ បាទ! ទទួលប្រជាជនហើយ ប៉ុន្តែរៀបចំកំលាំងនៅតាមច្រកៗហ្នឹង។

បូលីៈ កងពលប៉ុន្មានដែលអ៊ំទៅទទួលលើភ្នំវិញ?

វ៉ែនៈ អត់មានកងពលទេ ។

បូលីៈ ចុះ៨០២ពីណាគេ?

ដានីៈ ពីណាធ្វើប្រធាន៨០២?

វ៉ែនៈ ខ្ញុំក្ដាប់មិនបានទេ ។

បូលីៈ អីចឹង៨០២នេះនៅលើភ្នំ១០០១ដែរ?

វ៉ែនៈ បាទ! នៅលើភ្នំ១០០១ ។

បូលីៈ បើយើងរាប់ទៅវា៧កងពល គ្រាន់តែចេញពីភ្នំ១០០១ ។ ត្រូវទេអ៊ំ?

វ៉ែនៈ ត្រូវហើយ ។

បូលីៈ ៦កងពលនៅលើភ្នំ១០០១ ខាងនេះសុទ្ធតែ៩៨០, ៩១២, ៩៩០, ៧៨៥, ៦១៦ នេះសុទ្ធតែ១០០៣ទេ អត់នៅ១០០១ទេ ។ ច្រើនគន្ទាក់ដែលអ៊ំយើងគិតមើលទៅ ។

វ៉ែនៈ បាទ! ច្រើនគន្ទាក់ ។

បូលីៈ ៦កងពល ចុះ៧កងពលនៅលើភ្នំ១០០១ហ្នឹងចុះមកធ្វើការខាងក្នុង ចុះមកធ្វើការខេត្តណាខ្លះអ៊ំ? ឧទាហរណ៍ថា៦០៧ដែលអ៊ំកាន់ហ្នឹង មុនពេលឆន មកកាន់៦០៧ ធ្វើការនៅមុំណាខ្លះ?

វ៉ែនៈ ខ្ញុំធ្វើការមុំកូនក្អែក, មុំចង្ហូរ, តស៊ូខ្នាក់វាលរំពាក់ ខាងជើងកំពង់ធំ ។

បូលីៈ នៅខាងជើងកំពង់ធំ?

វ៉ែនៈ បាទ!

ដានីៈ ជាប់ព្រះវិហារវិញ?

វ៉ែនៈ បាទ!

ដានីៈ ចុះខាង៨០០ទៅខាងណាវិញ? ខាងកងពល៨០០?

វ៉ែនៈ ខាង៨០០មែនទែនកងដឹកជញ្ជូន ។

បូលីៈ បានន័យថាជញ្ជូនគ្រាប់ ជញ្ជូនស្បៀងមកឲ្យអ្នកខាងក្នុង?

វ៉ែនៈ បាទ!

បូលីៈ មានខេត្តណាទៀតដែលខាង១០០១ ចុះមកធ្វើការ?

វ៉ែនៈ ទេ ខ្ញុំដឹងតែផ្លូវខ្ញុំទេ ។

បូលីៈ ដឹងតែផ្លូវអ៊ំ?

វ៉ែនៈ បាទ!

បូលីៈ អីចឹង៨០២អ៊ំអត់ទទួលកងពលបន្ទាប់ពីឆន ទេ? ពេលឆន ផ្លាស់មក៦០៧?

វ៉ែនៈ អត់ទេៗ ។

ដានីៈ អីចឹងអ៊ំពេលដែលយើងឡើងទៅដល់លើភ្នំដំបូង មានតែ៨០១, ៩២០ ហើយនិង៤១៧ អីចឹង?

វ៉ែនៈ បាទ!

ដានីៈ ដល់ពេល៨០១ដំបូង ក្នុងកងពលមានពីណាខ្លះ?

វ៉ែនៈ ៨០០?

ដានីៈ ៨០១គណៈកងពលដែលអ៊ំឡើងទៅ ។ ពេលនេះយើងឡើងមកដកវែក កាលហ្នឹងមានសល់ពីណាខ្លះដែលជា?

វ៉ែនៈ មានតែតាក់នោះឯង ។

ដានីៈ មានតែតា០៥?

វ៉ែនៈ ០៥, ០៦ ។

ដានីៈ ០៥គាត់កាន់៨០១ ដល់ពេល០៦កាន់៩២០ ហើយអ៊ំនៅក្នុងគណៈកងពលហ្នឹងដែរ?

វ៉ែនៈ អត់ទេ ។

ដានីៈ អត់មាននៅក្នុងគណៈកងពល៨០១ទេ?

វ៉ែនៈ អត់ទេ ។

ដានីៈ កាលហ្នឹងអ៊ំជាស្អីវិញ?

វ៉ែនៈ ខ្ញុំមកនៅ៦០៧វិញហើយ ។

ដានីៈ ៦០៧ហ្នឹងបំបែកពីអន្លង់អីចឹង?

វ៉ែនៈ បំបែកនៅលើភ្នំ ។

ដានីៈ ពេលទៅដល់លើភ្នំបំបែកភ្លាម?

វ៉ែនៈ បាទ!

ដានីៈ មកបំបែកទៅបាន៦០៧?

វ៉ែនៈ បាទ!

ដានីៈ ដល់ពេលបំបែក៦០៧បានឈ្មោះអ៊ំ ជាប្រធានកងពល តាញ៉ាន់ ជាអនុ?

វ៉ែនៈ បាទ!

ដានីៈ កាលហ្នឹង៨០១បំបែកជា៦០៧ ចុះ៨០២បំបែកពេលហ្នឹងដែលឬអត់ទេ?

វ៉ែនៈ ហ្នឹងក្តាប់មិនបានទេ ។

ដានីៈ ចុះ៨០០ បំបែកពេលណាដែរ?

វ៉ែន:	៨០០បំបែកដំណាលខ្ញុំ ។

ដានី:	បំបែកដំណាលនឹង៦០៧?

វ៉ែន:	បាទ!

ដានី:	ចុះអឹមួយទៀតម៉េចបានគេដាក់លេខកងពល៦០៧វិញ?

វ៉ែន:	មិនដឹងម៉េចគេដាក់អីចឹង ។ តាមពិត៦០៧មានតែ២វរសេនាធំទេ មែនទែនមានតែ១០០ទេ ១១០នាក់តែប៉ុណ្ណឹង ។

បូលី:	កំលាំង?

វ៉ែន:	បាទ!កំលាំង ។

ដានី:	កំលាំង១វរសេនាធំតែ១១០នាក់ទេ?

វ៉ែន:	២វរសេនាធំ ។

ដានី:	២ហ្នឹងតែមួយរយនាក់ជាងទេ?

វ៉ែន:	២១០នាក់ ។

ដានី:	២១០នាក់ ចុះមួយកងពលហ្នឹងមានតែ២១០នាក់?

វ៉ែន:	បាទ! ចាប់ថ្មីហើយយកទៅធ្វើការ យើងរកកំលាំង ។

ដានី:	បានន័យថាឲ្យយើងទៅប្រមូលកំលាំងថែមទៀតឲ្យបានពេញមក?

វ៉ែន:	បាទ!

ដានី:	តែពេលអឹទៅធ្វើការបាន?

វ៉ែន:	ហ្នឹងមួយ ជួនកាលអ្នកណាដែលមានមនោសញ្ចេតនាជាមួយយើងទៅ ឃើញយើងស្រួលបួលគេមកនៅ ។

ដានី:	វរសេនាធំអីគេខ្លះទៅដំបូង ៦០៧វរសេនាធំលេខប៉ុន្មាន?

វ៉ែន:	មិនចាំទេខ្ញុំ ។

ដានី:	មានកំលាំងតែ២១០នាក់?

វ៉ែន:	បាទ!

ដានី:	ហើយពេលដែលអឹចុះទៅធ្វើការប្រមូលកំលាំងបានច្រើនទៀតអត់?

វ៉ែន:	អត់ទេ ។ ប្រមូលបានតែកំលាំងតាមកងចាស់ៗ អ្នកណាគេស្គាល់ ជាសញ្ចេតនាគេធ្លាប់រស់នៅ បេះតែមក ។

បូលី:	ពេលចុងឆ្នាំ៨៤ ដើម៨៥ ពេលដែលវៀតណាមធ្វើប្រតិបត្តិការបោសសំអាតតាមព្រំដែន ពេលហ្នឹង១០០១រំលំបុរនៅដដែល?

វ៉ែនៈ ខ្ញុំចង់និយាយថា ពេលវៀតណាមវ៉ៃតាមព្រំដែនខ្ញុំនៅចាអោក ។

បូលីៈ មកធ្វើការខាងក្នុង?

វ៉ែនៈ បាទ! នៅក្នុង ។

ដានីៈ នៅណាវិញ?

វ៉ែនៈ នៅចាអោក-អូរពោធិ៍ ។

ដានីៈ ចារអោក-អូរពោធិ៍ក្នុងស្រុកអីគេ?

វ៉ែនៈ ស្រុកសាលាវិស័យ ។

ដានីៈ ស្រុកសាលាវិស័យខេត្តព្រះវិហារ?

វ៉ែនៈ ខេត្តកំពង់ធំ ។

បូលីៈ អីចឹងអ៊ំនៅខាងក្នុង?

វ៉ែនៈ នៅក្នុងទេ គេវ៉ៃគ្នាប្របូកប្របល់ហើយ លឺសូរតែសំលេងគ្រឹងៗ ។

ដានីៈ ១០០១រត់ចូលមកខាងនេះវិញ អីចឹងអ៊ំ?

បូលីៈ រត់មកលិច?

ដានីៈ រត់មកខាងជាំ? មកខាងអូរគ្រាវ, ស៊ឹងចាន់វិញ អ៊ំ?

វ៉ែនៈ អីចឹងហើយ ព្រោះពី១០០១មកនៅនេះទាំងអស់ ដល់ពេលខ្ញុំឡើងមកចុះមកវិញ ចុះមក នៅម្តុំនេះវិញ ចុះតាមអាចម្តុំស៊ឹងចាន់ ។

បូលីៈ អ្នកនៅខាងក្នុងនេះ ពេលវៀតណាមវ៉ៃព្រំដែនយើងនៅខាងក្នុង?

វ៉ែនៈ បាទ!

បូលីៈ មានដឹងពីសភាពការណ៍ថាវៀតណាមកំពុងតែវ៉ៃដេញខ្មែរក្រហមតាមព្រំដែនទេ?

វ៉ែនៈ អត់ ។

បូលីៈ បានដឹងទេពេលហ្នឹង?

វ៉ែនៈ អត់ដឹងទេ ។

បូលីៈ អត់ដឹងទេ?

វ៉ែនៈ បាទ!

បូលីៈ អីចឹងយើងធ្វើសកម្មភាពធម្មតា?

វ៉ែនៈ ធម្មតា ។

បូលីៈ អត់បានដឹងពីសភាពការណ៍ព្រំដែនសោះតែម្តង?

វ៉ែនៈ អត់ទេ ។

បូលីៈ គ្រាន់យើងមានគេអូទាក់ទងគ្នា?

វ៉ែនៈ មានតែគេអត់ប្រាប់យើងទេ ។

បូលីៈ កាលដែលយើងចុះ?

វ៉ែនៈ បើសិនជាប្រាប់ជូនកាលយើងមានប្រពន្ធ-កូននៅនេះ ជួនកាលមកពីក្នុងអស់ មកដោះស្រាយរឿងកូន-ប្រពន្ធនេះចោលសមរភូមិ អីចឹងអត់ឲ្យដឹង ។

បូលីៈ គេអត់ប្រាប់ថាភ្នំ១០០១នេះរលំហើយ នាំគ្នារត់មក១០០៣គេអត់ប្រាប់យើងដឹងទេ?

វ៉ែនៈ អត់ទេ ។

បូលីៈ ពេលអ៊ំដឹង ដឹងពេលណា ដឹងពីក្រោយមកទេ?

វ៉ែនៈ ដល់ពេលដឹងអស់ពីនោះហើយបានដឹង មកឃើញនៅនេះអស់ហើយ ។

បូលីៈ ពេលដែលយើងឡើងទៅវិញ ដំណើរនៃការឆ្លងកាត់ពីកន្លែងធ្វើការទៅភ្នំ១០០១ ឬភ្នំ ១០០៣ យើងដើរត្រូវឆ្លងកាត់ទាហានយួន ទាហានរដ្ឋាភិបាលអីចឹង?

វ៉ែនៈ បាទ!

បូលីៈ អីចឹងយើងធ្វើម៉េចដើម្បីបញ្ចៀសមិនឲ្យមានគ្រោះថ្នាក់ មិនឲ្យជួបប្រទះគ្នាបាន ពេលយើងត្រឡប់ទៅវិញ ឬធ្វើដំណើរមក? យុទ្ធសាស្ត្រហ្នឹងយ៉ាងម៉េច?

វ៉ែនៈ ពីព្រោះឧបមាថានេះដូវយើងចុះ ធម្មតាយើងមានកំលាំងយើងនៅនេះ នេះដូវយើងឡើងនៅនេះទាំងអស់ ឥឡូវកន្លែងណាត្រូវគេប្រាប់ថាមកចំណុចក មកនេះ មកចំណុចខមកនេះ ហើយពេលវេលាម៉ោងត្រូវទាក់ទងគ្នាម៉េចៗគេដឹង ។

បូលីៈ បានន័យថាអ្នកដែលមកមុនហ្នឹង គេប្រាប់អំពីទីតាំងរបស់ខ្មាំង អំពីស្ថានភាពភូមិសាស្ត្រយើងត្រូវដើរយ៉ាងម៉េចៗ ដើម្បីកុំឲ្យជួបខ្មាំង?

វ៉ែនៈ ហ្នឹងហើយ ។

បូលីៈ កាលដែលចុះមកខាងក្នុងហ្នឹងយើងធ្វើកិច្ចការអីខ្លះ?

វ៉ែនៈ ចុះទៅដល់ភូមិគឺមានភារកិច្ចរបស់ទាហាន ទី១គឺ ការងារប្រជាជន អប់រំប្រជាជនឃោសនាប្រជាជន ។

ដានីៈ អប់រំ ឃោសនាជាមួយប្រជាជន?

វ៉ែនៈ បាទ!

ដានីៈ ឃោសនាយ៉ាងម៉េច? អប់រំយ៉ាងម៉េច?

វ៉ែនៈ ឧទាហរណ៍ចង់និយាយពីកន្លែងខ្ញុំទេ កន្លែងផ្សេងៗអត់ដឹងទេ ការពិតមួយជីវិតខ្ញុំនេះកន្លែងណាដែលលំបាកគេឲ្យខ្ញុំទៅកន្លែងនោះ ដកក្លាមទៅ ។ ទៅដល់ខ្ញុំជួបតាមព្រៃថាជីវិតភាពរបស់

អ៊ំនៅក្នុងព្រៃនេះ ហើយបើជួបខ្ញុំហ្នឹងហើយអ៊ំនាំភ្ញៀវ នាំខ្មាំងមករកវ៉ៃខ្ញុំ បើមិនឃើញថាអ៊ឹងឯងភរ ហើយទី២ខ្ញុំអត់នៅត្រង់ហ្នឹងទេ ខ្ញុំជួបអ៊ឹងឯងថ្ងៃនេះ ខ្ញុំទៅនោះបាត់ហើយ ទៅដើរប៉ះចំពួកខ្ញុំ ពួកខ្ញុំវ៉ៃផាប់ពួកទាហាន គេរករឿងអ៊ឹងឯង ហើយសេដ្ឋកិច្ចអ៊ឹងឯងនៅក្នុងព្រៃ នៅហ្នឹងវល្លិ៍ជ័រ តើជួបហើយរកអីរកទៅវិញទៅ កុំទៅប្តឹងផ្តល់ខាតតែផលប្រយោជន៍អ៊ំទេ វ៉ៃខ្ញុំម៉េច អ៊ឹងឯងឃើញទេ ផ្ទះខ្ញុំ កៅស៊ូខ្ញុំដំបូលស្រាប់ មិនបាច់ឲ្យគេមកវ៉ៃទេ និយាយជាមួយគាត់អ៊ីចឹង ។ កន្លែងណាដែលតឹងតែងមែនទែនជួបខ្ញុំហើយស្រួល អត់មានដែលនាំទាហានហើយថ្ងៃក្រោយជួបគាត់ទៀតនិយាយអ៊ីចឹងទៀត ។

បូលី: បានន័យថាយើងពង្រឹងស្មារតីគាត់ហើយស្រេច កុំឲ្យគាត់ទៅរាយការណ៍ឲ្យខាងក្នុង តែកាលណាគាត់ហ៊ានរាយការណ៍ឲ្យខាងក្នុង គាត់ត្រូវបាត់បង់សេដ្ឋកិច្ចខាងនេះ ព្រោះសេដ្ឋកិច្ចគាត់ផ្សារភ្ជាប់នឹងព្រៃនៅខាងក្នុង មានជ័រឈើ ។

វ៉ែន: ហើយមែនទែនតាមរយៈហ្នឹង អង្ករ អត់ស៊ី មានស៊ី តាមរយៈគាត់ ។

បូលី: យើងបានទទួលជំនួយម្ហូបអាហារ សម្ភារៈផ្គត់ផ្គង់ពីប្រជាជនទេលោកអ៊ំពេលហ្នឹង?

វ៉ែន: ទទួល យើងទិញគាត់ ។

បូលី: ដាក់ស្តែងទៅក្រៅពីការផាវធ្វើការជាមួយប្រជាជនដូចដែលអ៊ំមានប្រសាសន៍មិញ តើយើងមានធ្វើការអូសទាញប្រជាជនដើម្បីឲ្យចូលមកខាងយើងទេ?

វ៉ែន: អត់ទេ អ៊ឹងឯងចូលមកខាងខ្ញុំទៅព្រោះខ្ញុំតស៊ូលំបាក គាត់ថាហេតុផលដូចខ្ញុំបញ្ជាក់មិញអ៊ីចឹងសេដ្ឋកិច្ចអ៊ំនៅក្នុងព្រៃ វល្លិ៍ ជ័រ ទាក់សត្វ ហើយបើអ៊ំប្តឹងគេមិនឲ្យចេញចូលក្នុងព្រៃ អ៊ឹងឯងបានអី ។ វ៉ៃខ្ញុំអីខ្ញុំជួបអ៊ឹងឯងហ្នឹងខ្ញុំទៅដេកណាបាត់ ទំរាំទាហានមករកខ្ញុំឃើញរករឿងអ៊ឹងឯងទៀត និយាយតែប៉ុណ្ណឹង ។

បូលី: ខ្ញុំពេលដែលនៅខាងតំបន់ខាងក្រចេះ តែងតែលឺសូរមានការប្លន់ ឬបាញ់យករបស់របរពីប្រជាជន តើមានខ្លះទេករណីអ៊ីចឹងៗ?

វ៉ែន: អាហ្នឹងក្តាប់អត់បាន តែសំរាប់ខាងខ្ញុំមិនដែលទេ ខមថាវ៉ៃនៅទីតាំងណា ផ្ទះនៅជាប់ទីតាំងហ្នឹងមានបាត់វិទ្យុ ឲ្យតែដឹងដល់ខ្ញុំឲ្យរកទាល់តែឃើញយកឲ្យគាត់វិញ មិនមែនជារបស់ទាហាន ដល់យើងធ្វើអីចឹងអត់មានអ្នកណានៅជាមួយយើងទេ នៅខាងក្រចេះខ្ញុំលឺសូរអីចឹងដែរតែមិនដែលទេ ។

បូលី: បើយើងធ្វើអីចឹងបាត់ការជឿជាក់ពីប្រជាជន?

វ៉ែន: បាទ! ហ្នឹងហើយ ។

បូលី: អ៊ំពេលដែលអ៊ំចុះមកធ្វើការនៅខាងក្នុងអីចឹង មុនចុះមកមានទទួលការអប់រំពីថ្នាក់លើទេ?

វ៉ែនៈ ទទួល ទទួលការអប់រំពីថ្នាក់លើ គឺថាទី១ ធ្វើអីកុំឲ្យប៉ះពាល់ប្រជាជន ។ របស់របរកុំឲ្យប៉ះឲ្យសោះតាំងពីកូនចៅ ហើយថ្ងៃដំបូងដែលខ្ញុំឡើងមកនៅលើភ្នំនេះ ចុះទៅធ្វើការតាម៉ោកតាអោក ដំណាក់តស៊ូនេះ ទៅតែ៤-១០ដំបូងរកអង្ករស៊ីមិនបានទេ ដល់អីចឹងប្រមូលប្រជាជនមកធ្វើការងារ ថាខ្ញុំបើបងប្អូនអត់លក់អង្ករឲ្យក៏ខ្ញុំអត់ធ្វើបាបបងប្អូនទេ បើលក់ៗបើមិនលក់អត់ និយាយឃោសនាលើគាត់ទៅ ស្អែក ខានស្អែក បងប្អូន អន្តភាពទៅប្រាស្រ័យទាក់ទងល្អជាមួយគាត់ គាត់ចេះអាណិត ចេះតែឲ្យ យូរៗទៅចង្រ្កងជាមួយគ្នាបាន ។

បូលីៈ មកមួយក្រុមអីចឹងប្រហែលជាប៉ុន្មាននាក់ ពេលចុះមក?

វ៉ែនៈ ទេ តាមពិតមួយក្រុមមាន១២នាក់ មួយកងធំមាន១៥០ ប៉ុណ្ណឹងឯង ។

បូលីៈ ដែលយើងចុះមកហ្នឹងយើងចុះមកជាក្រុម ឬចុះមកជាកង?

វ៉ែនៈ អត់ទេ ចុះមកបែងចែក ពួកខ្ញុំចុះទៅធ្វើការម្តង២០០ ទៅដល់បំបែកគ្នា ឧបមាទៅត្រពាំងប្រាសាទ២០នាក់ទៅ ទៅអន្លង់វែង២០នាក់ ទៅមុខ២០នាក់ ចែកគ្នាទៅ ។

បូលីៈ បានន័យថាទាំង១០០នាក់ហ្នឹង ចុះមកមួយដុំសិនបានបំបែកគ្នាតាមក្រោយ ឬបំបែកតាំងពីលើ?

វ៉ែនៈ ទៅដល់កន្លែងមេបញ្ជាការនៅត្រង់ណាគេចាត់ចែង ។

បូលីៈ បន្តទៀត?

វ៉ែនៈ បាទ! បន្តទៀត ។

បូលីៈ មិនមែនបំបែក១២នាក់មួយក្រុម តាំងពីលើហើយមកទេ?

វ៉ែនៈ អត់ទេ ។

បូលីៈ ពេលដែលយើងចុះមកហ្នឹងអ្វីខ្លះដែលយើងយកមកតាមខ្លួន ក្រៅពីអាវុធយុទ្ធភណ្ឌ?

វ៉ែនៈ មានតែសារុង, ក្រណាត់, លុយកាក់ ។

បូលីៈ លុយហ្នឹងលុយអីគេ? លុយខ្មែរឬលុយបាត?

វ៉ែនៈ លុយខ្មែរ ។

បូលីៈ លុយរបស់រដ្ឋាភិបាលខាងក្នុង?

វ៉ែនៈ បាទ!

បូលីៈ ពេលអ៊ំធ្វើការនៅខាងក្នុងអីចឹងកាលពីសម័យហ្នឹង ក្នុងចិត្តអ៊ំគិតថាមានសង្ឃឹមទេពេលហ្នឹង

វ៉ែនៈ មានសង្ឃឹមអី?

បូលី៖ មានសង្ឃឹមថាយើងនឹងអាចតស៊ូបានជ័យជំនះ ឡើងវិញម្ដងទៀតទេ? ក្នុងចិត្តអ៊ំពេលធ្វើការខាងក្នុង?

វ៉ែន៖ ទេ ដូចថាតាមខ្ញុំមើលដូចលំបាកដែរ តែបើថាយើងប្រើតាមយោធាដូចតឹងតែងដែរ ខាងនយោបាយចេះតែពន្យាៗ ប្រជាជនស្រឡាញ់យើង យើងធ្វើល្អ យើងធ្វើត្រឹមត្រូវ យើងអាចបើប្រៀបធៀបនឹងសន្លឹកឆ្នោត អាច ប្រើខាងយោធាតឹងដែរ។

បូលី៖ មានសង្ឃឹមថាយើងអាចដេញយួនចេញ ហើយយើងនឹងអាចចូលមកកាន់កាប់ប្រទេសវិញឬយ៉ាងម៉េច?

វ៉ែន៖ អត់មានសង្ឃឹមទេ។

បូលី៖ អត់ដល់ហ្នឹងទេ?

វ៉ែន៖ បាទ!

បូលី៖ មានសង្ឃឹមត្រឹមណាអ៊ំពេលហ្នឹង?

វ៉ែន៖ អត់មានសង្ឃឹម ព្រោះប្រទង់ប្រទាញគ្នាអីចឹង។

បូលី៖ គេរត់ដោយគេ យើងរត់ដោយយើង?

វ៉ែន៖ បាទ! ហ្នឹងហើយ។

បូលី៖ ពេលណាដែលអ៊ំវិលទៅភ្នំ១០០៣វិញ? អ៊ំចុះមកធ្វើការម្ដងប៉ុន្មានឆ្នាំ?

វ៉ែន៖ ១ឆ្នាំបានឡើងម្ដង។

បូលី៖ ឡើងទៅម្ដងសំរាកបានប៉ុន្មានបានចុះមកទៀត?

វ៉ែន៖ មួយអាទិត្យអី។

បូលី៖ បានតែមួយអាទិត្យទេ?

វ៉ែន៖ បាទ!

បូលី៖ ដូចថាអ៊ំរៀបគ្រួសារម្ដងទៀត រៀបនៅលើភ្នំហ្នឹង ឬរៀបនៅណា?

វ៉ែន៖ រៀបលើភ្នំ។

បូលី៖ ភ្នំលេខប៉ុន្មាន?

វ៉ែន៖ ភ្នំពេទ្យអ៊ុំមជីថៃ។

បូលី៖ ១០០៣យើងនេះ?

វ៉ែន៖ បាទ!

បូលី៖ ឆ្នាំប៉ុន្មានដែលអ៊ំរៀបគ្រួសារទី២?

វ៉ែន៖ ភ្លេចបាត់ហើយ។

បូលីៈ ព្រោះ៨៥ខាង១០០១រត់មកខាង១០០៣?

វ៉ែនៈ បាទ!

បូលីៈ បើសិនជាអ៊ំរៀបនៅលើ១០០៣ ប្រហែលជាក្រោយ៨៥ គ្រាន់តែមិនដឹងប៉ែតប៉ុន្មាន ៨៦, ៨៧, ៨៨ ។

ដានីៈ ចុះកូនបង? កូនអ៊ំបងគេអាយុប៉ុន្មាន? ហើយការបានប៉ុន្មានឆ្នាំបានមានកូន?

វ៉ែនៈ មិនចាំអាយុកូនទេ ។

ដានីៈ កើតឆ្នាំអីទៅ? ឆ្នាំខ្មែរ?

វ៉ែនៈ អត់ដឹង ។

បូលីៈ កូនបងរៀនថ្នាក់ទីប៉ុន្មានហើយ?

វ៉ែនៈ ថ្នាក់ទី១ឈប់យូរហើយ ។

ដានីៈ ឈប់មានប្តី មានប្រពន្ធហើយ?

វ៉ែនៈ នៅរៀនអាពៅមួយ ។

បូលីៈ ទៅណាបាត់ហើយអាបង?

វ៉ែនៈ ទៅប្រូត ។

ដានីៈ អ៊ំនៅចាំផ្ទះ?

វ៉ែនៈ បាទ!

បូលីៈ បើសិនជួបអាបងអាចសួរដឹងអាយុបាន ហើយយើងដកឆ្នាំតាមហ្នឹង ។

វ៉ែនៈ បាទ ។

ដានីៈ អ៊ំមានប្រសាសន៍ថាក្រោយមកគេដកអ៊ំមកខាងលើវិញ ឆ្នាំណាគេដកមកលើវិញហ្នឹង?

វ៉ែនៈ អត់ចាំទេ ។

បូលីៈ ពិបាកគិត ។

វ៉ែនៈ បាទ!

ដានីៈ ពេលអ៊ំទៅនៅជាកងទ័ពចុះទៅខាងក្នុងអ៊ំរៀបការ ឬគេដកមកលើហើយបានរៀបការ?

វ៉ែនៈ ដកមកលើហើយ ។

ដានីៈ ដកមកលើហើយបានអ៊ំរៀបការ?

វ៉ែនៈ បាទ!

ដានីៈ អ៊ំពេលដែលយើងចុះមកនៅដំបូង ពីឆ្នាំ៩០កាលហ្នឹងកូនអាយុប៉ុន្មានឆ្នាំ កូនបង?

វ៉ែនៈ អត់ចាំទេ ។

បូលីៈ	នៅ១០០៣ មុន១០០២មក ១០០៣គេមានកំលាំងគេមួយដុំហើយតាម៉ុក គ្រប់គ្រង?

វ៉ែនៈ	ហ្នឹងហើយ ។

បូលីៈ	១០០១ពេលដែលបែកវៀតណាមវ៉ៃផ្តាច់ហ្នឹង មក១០០៣ មកនៅត្រង់មុំក្បាលស៊ីងចាន់?

វ៉ែនៈ	បាទ!

បូលីៈ	ចុះខាង១០០៣គេនៅម្តុំណាដែលដឹងទេ?

វ៉ែនៈ	គេនៅខាងលិចហ្នឹងទៀត ។

បូលីៈ	បានន័យថានៅខាងនេះ?

វ៉ែនៈ	បាទ!

បូលីៈ	នៅខាងលិចស៊ីងចាន់ហ្នឹង?

វ៉ែនៈ	បាទ!

បូលីៈ	មានឈ្មោះរបស់គេទេ? ឧទាហរណ៍ថា១០០១គេមានឈ្មោះគេស៊ីងចាន់ ចុះ១០០៣គេមានឈ្មោះគេទេ?

វ៉ែនៈ	អត់ទេ ខ្ញុំអត់ចាំ ។

បូលីៈ	ដាំស្វា, អូរគ្រាវ ហ្នឹងខាង១០០៣ឬ១០០១?

វ៉ែនៈ	ខ្ញុំអត់ដឹង ។

បូលីៈ	អ៊ំមានដឹងថាចន្លោះពីដាំស្រង៉ាំមកខាងលិចកងពលណាអ្នកទទួលខុសត្រូវទេអ៊ំ មកដល់អូរស្មាច់?

វ៉ែនៈ	អត់ដឹងទេ ។

បូលីៈ	មិនមែន៨០២ទេ?

វ៉ែនៈ	មិនមែនទេ ។

បូលីៈ	ចុះពេលហ្នឹងអ៊ំឡើងទៅលើភ្នំវិញ អ៊ំទទួលខុសត្រូវម្តុំណាវិញ?

វ៉ែនៈ	ខ្ញុំនៅតែពេទ្យអ៊ុំដដែលទេ ។

ដានីៈ	ពេទ្យអ៊ុំ?

វ៉ែនៈ	បាទ! ពេទ្យអ៊ុំអ៊ីម៉ុំា ម្តុំព្រំដែនលាវ-ព្រំដែនថៃ-ព្រំដែនខ្មែរ ។

បូលីៈ	មក១០០១វិញ?

វ៉ែនៈ	បាទ!

ដានីៈ	នៅជាមួយពីណាវិញ? អ្នកគ្រប់គ្រងប្រជាជនជាមួយអ៊ំពីណាខ្លះ?

វ៉ែន:	មានគាញ៉ាន់ ហ្នឹងឯង ។

ដានី:	គាញ៉ាន់ គាត់ឡើងមកលើដែរ?

វ៉ែន:	បាទ!

ដានី:	គេឲ្យតាឆន មកកាន់ហ្នឹង អ៊ំហើយគាញ៉ាន់ ឡើងទៅលើវិញ?

វ៉ែន:	ឡើងមកលើវិញ ។

ដានី:	ចុះអ៊ំនៅជាមួយអ៊ំអាន ដែលអត់ទេ?

វ៉ែន:	អត់ទេ ។

ដានី:	អ៊ំអាន គាត់គ្រប់គ្រងប្រជាជនដែរ?

វ៉ែន:	បាទ! ហ្នឹងគាត់ខាង១០០៣ហើយ ។

ដានី:	គាត់មកនៅខាង១០០៣វិញហើយ?

វ៉ែន:	បាទ!

ដានី:	អ៊ីចឹងអានេះវៀតណាមយកបានឆ្នាំ៨៤-៨៥?

វ៉ែន:	បាទ!

ដានី:	ចុះបើអ៊ំថា ពេលគេដកឡើងមកវិញ អ៊ំនៅខាងគ្រប់គ្រងពេទ្យអ៊ុំ នៅខាងមុំ៣ ជាន់ជាមួយវៀតណាម ឬក៏យ៉ាងម៉េច ខ្ញុំអត់ច្បាស់កន្លែងហ្នឹង?

វ៉ែន:	អត់ទេ ខ្ញុំនៅហ្នឹង តែខ្ញុំទៅធ្វើការនៅហ្នឹង ។

បូលី:	បានន័យវៀតណាមគ្រប់គ្រងតែកំលាំងខ្មែរក្រហមបញ្ជូនមួយកង១ មកធ្វើការតាមហ្នឹង?

វ៉ែន:	ទៅក្តាប់ ។

ដានី:	ក្តាប់ប្រជាជន?

វ៉ែន:	អត់ទេក្តាប់ខ្មាំង ។

បូលី:	ក្តាប់កន្លែង?

វ៉ែន:	បាទ!

ដានី:	កងស៊ើបការណ៍?

វ៉ែន:	បាទ!

បូលី:	អត់មានប្រជាជនទេអ៊ំកន្លែងហ្នឹង?

វ៉ែន:	អត់មានប្រជាជនទេ ប្រជាជនរត់មកនៅនេះអស់ហើយ ។

បូលី:	ប្រជាជនរត់មក១០០៣អស់ហើយ?

វ៉ែន:	បាទ!

បូលី៖	ដូចដែលកំលាំងខ្មែរក្រហមមកធ្វើការនៅក្នុងអីចឹង?
វ៉ែន៖	ហ្នឹងហើយ!
បូលី៖	គ្រាន់តែចុះមកធ្វើការខាងហ្នឹង ចុះមកធ្វើការមើលវៀតណាមឈរជើងនៅណា?
វ៉ែន៖	នៅត្រង់ណាៗ ។
បូលី៖	មានដែលប៉ះប្រទះគ្នា វ៉ៃគ្នាទេពេលហ្នឹង?
វ៉ែន៖	អត់ទេ ។
បូលី៖	អ៊ំមានដឹងប្រាសាទព្រះវិហារពេលហ្នឹងពីណាឈរជើងលើហ្នឹង? ៨៥, ៨៦, ៨៧?
វ៉ែន៖	ខ្ញុំលែងដឹងហើយ ។
បូលី៖	ឆ្ងាយទៀត?
វ៉ែន៖	បាទ!
ដានី៖	ពី៧៩មកខ្មែរក្រហមយើងកាន់កាប់? ពី៧៩-៨៤ ប្រាសាទព្រះវិហារ?
វ៉ែន៖	អីចឹងហើយ តែមានគេអ្នកកាន់កាប់ផ្សេង ។
បូលី៖	អ៊ំដែលដឹងទេ?
វ៉ែន៖	អត់ដឹងទេ ។
បូលី៖	យើងមិនបាច់សួរមកក្រោមទេ ។
ដានី៖	មិនបាច់ទេ ។
បូលី៖	ត្រឹមហ្នឹងបាន ។
ដានី៖	អ៊ំបន្ទាប់ពីដែលយើង ចុះមកនៅនេះឆ្នាំណា?
វ៉ែន៖	ក្តាប់មិនបានទេ ។
ដានី៖	អត់ចាំ ។
បូលី៖	ឆ្នាំអ៊ំលំបាកចាំ ។
វ៉ែន៖	ឆ្នាំលំបាកចាំណាស់ ។
ដានី៖	អ៊ំពេលដែលមានរឿងរ៉ាវ ក្រោយមកមានរឿងរ៉ាវ ក្រុមតាម៉ុក ហើយក្រុមតាប៉ុល ពត ហើយតាសុន សេន ត្រូវបានសម្លាប់ អ៊ំមានដឹងរឿងរ៉ាវហ្នឹង?
វ៉ែន៖	អត់ទេ អត់ដឹងទេ ។ គ្រាន់តែកាលហ្នឹងខ្ញុំនៅអុសពកទេ ដល់សភាពការណ៍គេឲ្យឡើងមកៗ មកដល់ខ្ញុំមកនៅ ប្រជាជននៅនេះអស់ហើយ ហើយដល់អីចឹង សភាពការណ៍ពេលនោះខ្ញុំមកអន្លុកភាពខ្ញុំនេះ មកភូមិនេះ ជាឥឡូវសភាពការណ៍វាចេះៗ សំរាប់ខ្ញុំវិញ ខ្ញុំអត់ទៅណាទាំងអស់ ខ្ញុំនិយាយជាមួយបងប្អូន អត់ទៅណាទេខ្ញុំលែងទៅហើយ បើអ្នកណាចង់ធ្វើអីខ្ញុំក៏

ធ្វើទៅ ខ្ញុំនិយាយនៅផ្ទះនេះ ហ្នឹងផ្ទះខ្ញុំមិនទាន់ធ្វើទេ ប្រមូលទាំងអស់ យុទ្ធជនទាំងចាស់ទាំងក្មេង ខ្ញុំអត់ទៅទៀតទេ ធុញទ្រាន់ណាស់ហើយ បើពីណាចង់ធ្វើអីខ្ញុំធ្វើទៅ អ្នកណាចង់ទៅក៏ទៅៗ តែបើទៅស្រុកគេនាំតែលំបាកទេ កាំភ្លើងគ្រាប់ទុកចោលនេះទៅ ហើយទៅតែខ្លួនបើអ្នកចង់ធ្វើអីខ្ញុំធ្វើអី ។

ដានី: ព្រឹត្តិការណ៍ដែលរឿងតា០៥, ០៦ ខាងតាម៉ុកចាប់ ហើយអ៊ីកាលហ្នឹងគេអត់មានប៉ះពាល់អ៊ីទេ?

វ៉ែន: អត់ទេ ។

បូលី: ពេលវ៉ៃគ្នា ពេលដែលកំលាំងរបស់តាម៉ុក ហើយនិងកំលាំងរបស់តាប៉ុល ពត វ៉ៃគ្នាពេលហ្នឹងអ៊ីនៅណា?

វ៉ែន: ខ្ញុំនៅនេះ ដល់ស្រអែមហើយ ។

បូលី: នៅស្រអែមនេះ?

វ៉ែន: មកពីនោះវិញហើយ ។

បូលី: មកពី១០០១វិញហើយ?

វ៉ែន: អត់ទេមកពូអូរពោធិ៍ហើយ ។

ដានី: អូរពោធិ៍នៅសាលាវិស័យ?

វ៉ែន: ហ្នឹងហើយ ដល់ស្រអែមហើយឃើញសំបុត្រ០៥ ឲ្យខ្ញុំរៀបចំកំលាំងទៅជួបគាត់នៅភ្នំតែប៉ុណ្ណឹងទេ ។

ដានី: ហើយអ៊ីទៅអត់?

វ៉ែន: ខ្ញុំអត់ទៅ ថាអត់ទៅទេ ប្រាប់ពួកខ្ញុំថាមិនបាច់ទៅទាំងអស់ អ្នកណាធ្វើអីធ្វើទៅ ។

បូលី: ហើយសំបុត្រហ្នឹងសរសេរថាម៉េច?

វ៉ែន: សរសេរជូនខ្ញុំ ថាឲ្យរៀបចំកំលាំងកងទ័ពទាំងអស់ឲ្យមកជួបគាត់នៅកន្លែងនេះ កន្លែងនោះក្បាលទន្សោង តែសំរាប់ខ្ញុំដឹងថាទៅច្បាស់ជាមានឲ្យវ៉ៃនេះ នោះ តែខ្ជិលទៅណាស់ ប្រាប់បងប្អូនថាមិនបាច់ទៅ បើអ្នកណាមកហៅទៅណាមិនបាច់ទៅ បើអត់ពីខ្ញុំប្រាប់ អត់ទៅទេ ។ ដល់អីចឹងឃើញនីរសាតាម៉ុក ៤នាក់ម៉ូតូ២ មកផ្ទះខ្ញុំខាងនៅកើត អាទុះសៀទេ អាការសួរថាអ៊ីនៅណា ខ្ញុំនៅនេះ ហើយមានអី ថាអញ្ជើញអ៊ីឲ្យទៅជួប ថាអត់ទៅទេ ទៅចុះ វាទៅវិញ ។ ដល់អីចឹងខ្ញុំគិតថា តាម៉ុក ប្រតិកម្មហើយ ឲ្យទាហានមករករឿង ដល់អីចឹងខ្ញុំថាពួកយើងរៀបចំ តាម៉ុក ឲ្យពួកហ្នឹងមកតាមខ្ញុំ តែខ្ញុំមិនទៅ អាចគាត់ប្រើកំលាំងអីផ្សេងទៀត ដល់អីចឹងគេថាឲ្យតែមក ។ នៅលើភ្នំកំពុងក្តុងក្តាំងមួយៗ កំពុងតែវ៉ៃគ្នា វ៉ៃហើយវា

ស្វាត់ តែយូរៗលឺគ្រាប់ ហើយពួកខ្ញុំខ្លាចតាម៉ុក ដឹកកំលាំងមក ពួកខ្ញុំតាំងពីស្ពានតូចនេះ ដល់អ៊ីចឹង លា ប្រាប់ថាពួកតាម៉ុកមក២ឡានស៊ីប ឥឡូវឈប់នៅតាមផ្លូវស្ពានធំ វ៉ៃគ្នា ឥឡូវអត់យូរទេ ដល់អ៊ីចឹងមកឃើញគេអូហៅឲ្យខ្ញុំទៅ ខ្ញុំថាអត់បានទៅទេ ខ្ញុំជាប់រវល់ ជាប់រវល់អី ថាជាប់រវល់រៀបចំឲ្យគ្រួសារខ្ញុំទៅនេះទៅនោះ អត់មកដែរ តែមកវ៉ៃហើយ

បូលីៈ កំលាំងអីប៉ុន្មាននាក់នៅនេះ?

វ៉ែនៈ ច្រើនដែរ ខ្ទង់៥០-៦០នាក់ៗ

ដានីៈ ៥០-៦០នាក់?

វ៉ែនៈ បាទ!

បូលីៈ អ៊ីចឹងតា០៥ ក៏មកហោអ៊ំ?

វ៉ែនៈ តែគេនៅជាប់លើ អត់ចុះមកនេះរួចទេៗ

បូលីៈ តាម៉ុក នេះក៏ចង់ហៅអ៊ំទៅដែរ?

វ៉ែនៈ ហ្នឹងហើយៗ

បូលីៈ ប្រទាញប្រទង់គ្នា?

វ៉ែនៈ ប្រទាញប្រទង់គ្នា តែខ្ញុំអត់ទៅៗ

បូលីៈ អ៊ីចឹងនៅក្នុងជម្លោះរវាងតាម៉ុក និងតាប៉ុល ពត ដែលបាញ់គ្នាអ៊ំអត់បានចូលរួមទេ?

វ៉ែនៈ អត់ទេៗ

បូលីៈ ពេលដែលគេចាប់បានតាប៉ុល ពត, តា០៥, ០៦ អ៊ំនៅនេះហើយ?

វ៉ែនៈ បាទ! ដល់នេះហើយៗ

បូលីៈ ឬអ៊ំនៅ?

វ៉ែនៈ អត់ទេ ខ្ញុំនៅនេះហើយ តែអត់ដឹងថាគេចាប់បានទេ ព្រោះខ្ញុំនៅនេះ គេចាប់បានណានោះ

បូលីៈ នៅលើភ្នំនោះៗ

វ៉ែនៈ បាទ!

ដានីៈ គេចាប់បានហើយយ៉ាងម៉េចទៀត តាម៉ុក មានមក?

វ៉ែនៈ អត់ទេៗ

បូលីៈ ព្រោះកំលាំងតា០៥, ០៦ នៅខាងត្រពាំងប្រាសាទ?

វ៉ែនៈ បាទ!

បូលីៈ ភាគច្រើនកំលាំងគាត់នៅខាងនេះ?

វ៉ែនៈ បាទ!

បូលី: កំលាំងតាម៉ុក នៅខាងអន្លង់វែង?

វ៉ែន: បាទ!

បូលី: ពេលដែលតាម៉ុក ចាប់បានតាប៉ុល ពត, តា០៥, តា០៦ គាត់មានបញ្ជូនកំលាំងមកធ្វើឃោសនា ឬបង្រ្កាបនៅត្រពាំងប្រាសាទទេ?

វ៉ែន: អត់ទេ អត់មានៗ

បូលី: គាត់អត់មានខ្វាចខាងត្រពាំងប្រាសាទលើកកំលាំងទៅប៉ះបោរទាមទារដោះលែង តា០៥វិញ?

វ៉ែន: អត់ទេៗ

ដានី: អ៊ំតាម៉ុក អត់មានមកទាក់ទង ឬអ៊ំអត់ទៅទាក់ទងតាម៉ុក បន្ទាប់ពីគេចាប់០៥ហើយ?

វ៉ែន: អត់មានទេៗ

ដានី: អ៊ំនៅស្ងៀមនៅហ្នឹងទៅ?

វ៉ែន: នៅស្ងៀមៗ

ដានី: ហើយខាងកងទ័ព ខាងកំលាំងតាម៉ុក អត់មានមកទៀត?

វ៉ែន: មកវរសេនាធំដែលល្អ ដែលស្គាល់ គាត់ថាអាហ្នឹងចេះទេបង មនុស្សធ្លាប់ស្គាល់គ្នា រឿងរ៉ាវតែប៉ុណ្ណេះទេ ពីព្រោះបងអ្នកគ្រប់គ្រងកំលាំងដែរ និយាយរួមមានកំលាំង ចង់តាម៉ុកហៅទៅជួបធ្វើម៉េចកុំឲ្យកំលាំងហ្នឹងទៅជួយវ៉ៃប៉ុល ពត ទៅជួយវ៉ៃ០៥ ហើយបដិសេធន៍ឈប់ទទួលការដឹកនាំប៉ុល ពត គេនិយាយប្រាប់ខ្ញុំហ្នឹង និយាយប៉ុណ្ណឹងទេៗ

ដានី: ហើយពេលហ្នឹងអ៊ំថាម៉េច?

វ៉ែន: ខ្ញុំថាអត់ទៅខាងណាខាងណី ខ្ញុំអត់ទៅ ខ្ញុំចាំមើលសិនៗ

បូលី: បានន័យថាគេមិនធ្វើអីទេ តែសុំតែមួយគឺកុំទៅជួយប៉ុល ពត?

វ៉ែន: បាទ! ទៅជួយប៉ុល ពតៗ

បូលី: និង០៥, ០៦?

វ៉ែន: បាទ! អត់ទេកំលាំងរបស់តាម៉ុក ទេៗ កំលាំងរបស់តាម៉ុក មកជួបហ្នឹងមេៗ មកជួបខ្ញុំថាតាម៉ុក ហៅបងឯងទៅជួប ទី១គឺ កុំឲ្យបងឯងចូលរួមជួយ០៥, ០៦ និងតាពត នៅឲ្យស្ងៀមទៅ ខ្ញុំថា អញមិនទៅទេៗ

បូលី: អ្នកណាអ្នកមកប្រាប់? ចាំឈ្មោះទេ?

វ៉ែន: អត់ចាំទេៗ

បូលី: មិនមែនតាង៉ុន ទេ?

វ៉ែនៈ មិនមែនទេ ។

ដានីៈ មិនមែន នួន នៅ ទេ?

វ៉ែនៈ មិនមែនទេ ។

បូលីៈ ដែលមកប្រាប់ហ្នឹង មកប្រាប់តែអ៊ីម្នាក់ ឬគេហៅមេៗមកប្រាប់?

វ៉ែនៈ ប្រជុំ ។

បូលីៈ មានពីណាខ្លះចូលរួម?

វ៉ែនៈ គេមកប្រាប់យើង យើងហៅអ្នកដែលនៅជិតខាង ថាថ្ងៃនេះគេចង់ជួបហៅខ្ញុំទៅតែប៉ុណ្ណេះ គេថាឲ្យយើងទាំងអស់គ្នាឈប់ទទួលស្គាល់ប៉ុល ពត ទៅ ហើយកុំទៅជួយឧបត្ថម្ភជាកំលាំង តែប៉ុណ្ណឹងឯង ។

បូលីៈ ក្រោយមកពេលដែលចាប់ប៉ុល ពត, កាត់ទោសប៉ុល ពតអីហើយ កំលាំងខាងអន្លង់វែង មានមួយក្រុមគេបានទៅសហការជាមួយរដ្ឋាភិបាល ហើយក៏បានផ្ទុះអាវុធរវាងក្រុមដែល ទៅសហការជាមួយរដ្ឋាភិបាល យើងអាចនិយាយថាក្រុមពូផាន់ណា ជាមួយក្រុមតាម៉ុក ដល់ពេលហ្នឹងត្រពាំងប្រាសាទយើងមានរៀបចំកំលាំង ដើម្បីត្រៀមចុះចូលទេ?

វ៉ែនៈ អត់ទេ កាលហ្នឹងខ្ញុំនៅនេះ ផ្ទះខ្ញុំនេះ ប្តីត្បិតខ្ញុំនៅត្រពាំងប្រាសាទ តែផ្ទះខ្ញុំនៅនេះ កំលាំង មេៗត្រពាំងប្រាសាទ អន្លង់វែងដែលធ្លាប់ស្គាល់ ចង់មកនិយាយជាមួយខ្ញុំថ្ងៃហ្នឹងតែមិន ហ៊ាននិយាយ ចង់មកទាញខ្ញុំចេះៗ អត់ហ៊ាន ។ តែពេលដែលជួបខ្ញុំហើយគេទៅវិញ យប់ ហ្នឹងផ្ទុះកាំភ្លើង ខ្ញុំលឺសូរកាំភ្លើង ខ្ញុំក្រឡេកមកផ្ទះឃើញភ្លើងព្រុយៗ បាញ់៦០មួយគ្រាប់ ហើយដល់ព្រឹកឡើងបានមកដល់ យប់មិញខ្ញុំមកចង់ទាញបងឯងចេះៗ តែញញើត ។

បូលីៈ ខាងណា? ខាងពូផាន់ណា ឬខាងតាម៉ុក?

វ៉ែនៈ ខាងផាន់ណា ។

បូលីៈ មុននឹងផ្ទុះអាវុធធ្លាប់មកទាក់ទងអីដែរ?

វ៉ែនៈ បាទ!

បូលីៈ តែអត់ហ៊ាននិយាយទេ?

វ៉ែនៈ អត់ហ៊ាននិយាយ ។

បូលីៈ ព្រោះមិនដឹងថាអ៊ីច្បាស់លាស់ទៅខាងណា?

វ៉ែនៈ ហ្នឹងហើយច្បាស់លាស់ទៅខាងណា ។

បូលីៈ អ៊ីមានដឹងថាខាងត្រពាំងប្រាសាទ ខាងតាជុំ ជាតិ, ជា កែវ គាត់មានត្រៀមខ្លួនរៀបចំ កំលាំងចុះចូលទេ ឬយ៉ាងម៉េចពេលហ្នឹង?

វ៉ែនៈ គ្រៀមអី ពួកហ្នឹងសុទ្ធតែរត់អស់ហើយ រត់ទៅចូលរដ្ឋាភិបាលអស់ហើយ ។

បូលីៈ រត់ពីអន្លាល់? មុនផ្ទុះអាវុធហ្នឹងរត់យូរទេ?

វ៉ែនៈ រត់មុនផ្ទុះអាវុធ ក្រោយ ។

បូលីៈ មុនឬក្រោយ?

វ៉ែនៈ ក្រោយផ្ទុះអាវុធ ខ្ញុំជួប ជា កែវ បងយើងសុខចិត្តស្លាប់រស់ទាំងអស់គ្នា ទៅណាទៅទាំងអស់គ្នា ហ្នឹងតាកែវ និយាយជាមួយខ្ញុំ កុំក្បត់គ្នាឲ្យសោះ ហើយដល់ពេលអីចឹងទៅគាត់ប្រុច តែគេចូលខ្ញុំ ។

ដានីៈ សួរអីដែរ?

វ៉ែនៈ សួរ ។

ដានីៈ ថាអីទៅអត់?

វ៉ែនៈ អត់សួរអីចឹងទេ ទៅនោះគ្រប់គ្រងកំលាំងយើងទៅ តែខ្ញុំដាច់ខាតទៅណាក៏មិនចោលបងដែរ កុំភ័យខ្ញុំនិយាយជាមួយគ្នាម៉េចនិយាយអីចឹងហើយ គ្រាន់តែអីចឹងពេលកងទ័ពរដ្ឋាភិបាលមក ខាងនេះក៏មក ខាងនោះក៏មក គាត់គេមកខ្ញុំ បងនៅណា? ខ្ញុំនៅកន្លែងដែលហ្នឹងឥឡូវមកជួបគ្នានេះ ។ ថាហ្នឹងហើយខ្ញុំនាំកំលាំងទាំងអស់ទៅ ដល់អីចឹងនាំកំលាំងទៅជួប ។

បូលីៈ ជួបនៅម្តុំណា?

វ៉ែនៈ ជួបនៅទំនប់ អមជើងភ្នំទំនប់០៥ហ្នឹង ។

ដានីៈ ទំនប់ដាច់?

វ៉ែនៈ អត់ទេ ខាងនេះទំនប់ដាច់ ។

បូលីៈ ទំនប់០៥ ទំនប់ដែលគាត់មានធ្វើផ្ទះមួយចូលក្នុងទឹក?

វ៉ែនៈ អត់ទេ នោះទំនប់ដាច់ទេ មកក្រោមតិច នេះទំនប់អូរជីក នៅលើ ខាងលើផ្លូវ ។

បូលីៈ មានទំនប់មួយទៀតដែលយើងទៅអត់ដល់អីចឹង ។

វ៉ែនៈ បាទ!

ដានីៈ ពីភូមិ១០៥ទៅត្រង់?

វ៉ែនៈ ទៅចេះ ។

បូលីៈ អីចឹងតាជា កែវ វ៉ៃគេអូ ឬទូលេខ?

វ៉ែនៈ គេអូ ។

បូលីៈ គេអូមកអី?

វ៉ែនៈ បាទ!

បូលីៈ អីចឹងបានន័យពេលដែលពូផាន់ណា ហើយក្រុមតាម៉ុក ផ្ទុះអាវុធហើយបានតាផា កែវ ហើយនិងតាជុំ ជាតិ រត់?

វ៉ែនៈ បាទ!

បូលីៈ រត់ទៅចូលនៅជាមួយរដ្ឋាភិបាល?

វ៉ែនៈ បាទ!

បូលីៈ ពេលដែលគាត់មាននាំកំលាំងទៅ ឬទៅតែខ្លួនទេ?

វ៉ែនៈ នាំហើយ តែនាំតិចតួច ព្រោះកាលហ្នឹងខ្ញុំមិននៅផ្ទះទេ ខ្ញុំនៅខាងនោះត្រពាំងប្រាសាទ កំលាំងនៅជាប់ខ្ញុំច្រើនដែរ គ្រាន់តែគាត់រត់យប់នេះគាត់ប្រាប់ខ្ញុំ ហើយតាម៉ុក បេះតែបញ្ញាស្កាត់ៗ ។

ដានីៈ បញ្ញាកំលាំងអីឲ្យទៅស្កាត់ ឬក៏បញ្ញាកំលាំងផ្សេង?

វ៉ែនៈ បញ្ញាកំលាំងខ្ញុំ ពីព្រោះរត់កន្លែងនោះខ្ញុំនៅមុខស្រេចហើយ ។

ដានីៈ ដល់ពេលបញ្ញាអីឲ្យទៅស្កាត់ អ៊ំថាម៉េច?

វ៉ែនៈ ខ្ញុំថាបាទ ខ្ញុំចាត់ចែងឲ្យ ។

បូលីៈ តែបាទ តែមាត់?

វ៉ែនៈ បាទ! ដល់អីចឹងមានអី ពួកហ្នឹងទៅរកទិញថ្នាំ ផ្អាកមួយថ្ងៃ ផ្អាកធ្វើសកម្មភាពមួយថ្ងៃ ហើយល្ងាចយើងជួបជុំគ្នាតិច គេសំរាក ចាំស្អែកចាំធ្វើការ ។ មានអីគាត់គេចៗពួកខ្ញុំ ខ្ញុំថា ដើរមកអត់អីទេ កុំឲ្យតែដើរបុកកន្លែងគេ បើថាដើរ៥០-១០០ម៉ែត្រដើរទៅ ។

បូលីៈ តែបើសិនដើរមកប៉ះចំកំលាំងអ៊ំ ក៏អ៊ំលំបាកនឹងថាទេដែរពេលហ្នឹង?

វ៉ែនៈ បាទ! លំបាកអីយើងដឹងចំណុចហើយ កន្លែងនៅនេះៗ ។

បូលីៈ មុនពេលដែលគាត់រត់ទៅ គាត់មានលួចចរចារជាមួយរដ្ឋាភិបាលបណ្ដើរៗទេពេលហ្នឹង? មុនពេលរត់?

វ៉ែនៈ មិនដឹងយ៉ាងម៉េចទេ ។

បូលីៈ អ៊ំក្ដាប់អត់បានទេ?

វ៉ែនៈ ក្ដាប់អត់បានទេ ។

បូលីៈ ទាល់តែទៅសួរគាត់តែម្ដង?

វ៉ែនៈ បាទ!

បូលីៈ ហើយពេលដែលគាត់នាំកំលាំងរដ្ឋាភិបាលវ៉ៃចូលពីខាងស្រអែមមក អ៊ំផាន់ណា វ៉ៃចូលពីនេះមក ស្រែណូយ-អូរបាយតាប់?

វ៉ែនៈ បាទ!

បូលីៈ ពេលហ្នឹងកំលាំងអ៊ំនៅកណ្តាល?

វ៉ែនៈ ខ្ញុំនៅនេះ ។

បូលីៈ ហើយកំលាំងតាម៉ុក នៅអន្លង់វែង?

វ៉ែនៈ អន្លង់វែង ។

បូលីៈ ទប់ទល់ទាំងសងខាង?

វ៉ែនៈ បាទ!

បូលីៈ ពេលហ្នឹងគាត់ទាក់ទងតេអូមកអ៊ំ?

វ៉ែនៈ បាទ!

បូលីៈ ពេលហ្នឹងអ៊ំរៀបចំកំលាំងទៅជួបគាត់ម្តុំណា?

វ៉ែនៈ ខ្ញុំទៅជា កែវ កំលាំងខ្ញុំឡើងទៅអស់ នៅកំលាំងតាម៉ុកនៅនេះ ។

ដានីៈ ចុះខាងតាម៉ុក មានទាក់ទងមកអ៊ំទេ?

វ៉ែនៈ អត់ទេ ។ ដល់ពេលកងទ័ពពួកដាន់ណា មកវ៉ៃគ្នានៅស្វាយចេកនេះ គាត់សួរកំលាំងខាងណា កំលាំងបង អត់ទេកំលាំងខ្ញុំអត់មាននៅសល់ម្នាក់ទេ នៅនេះទាំងអស់នៅជាប់ខ្ញុំ ខ្ញុំជួបកែវ នោះ ។

បូលីៈ នៅត្រពាំងប្រាសាទនេះមានកំលាំងណាដែលនៅសេសសល់ នៅតែបន្តគាំទ្រតាម៉ុក ទៀត

វ៉ែនៈ ដូចមិនមានទេ ។

បូលីៈ មានតែប្រជាជន?

វ៉ែនៈ បាទ!

បូលីៈ តែប្រជាជនហ្នឹងគ្រួសារកងទ័ពដែរ?

វ៉ែនៈ បាទ!

បូលីៈ មានមេដឹកនាំនៅបន្តតស៊ូទៀតទេ មុនពេលចុះចូលហ្នឹង? ពេលពូដាន់ណា វ៉ៃចូលមក ពូ ជា កែវ វ៉ៃចូលមក?

វ៉ែនៈ ទេ អត់មានទេ ។

ដានីៈ អ៊ំពូ វ៉ាន់ កុសល កាលហ្នឹងពេលគេវ៉ៃគ្នាគាត់ទៅខាងភូណយ ជាមួយតាម៉ុក ។

វ៉ែនៈ បាទ!

ដានីៈ ហ្នឹងយ៉ាងម៉េចបានជាគាត់ទៅ?

វ៉ែនៈ មិនចឹងយ៉ាងម៉េច តាមមើលជម្លៀសប្រពន្ធទៅ គាត់ទៅតាមទេ ។

ដានី៖ មិនមែនគាត់ទៅចូលជាមួយតាម៉ុកទេ?

វ៉ែន៖ មិនមែនទេ ។

បូលី៖ គាត់កាន់កំលាំងមួយនៅហ្នឹងដែរ?

វ៉ែន៖ បាទ ។

បូលី៖ នៅត្រពាំងប្រាសាទយើងហ្នឹង?

វ៉ែន៖ បាទ!

ដានី៖ ដល់ពេលអ៊ំទៅចូលជាមួយខាងអ៊ំជា កែវ, ជុំ ជាតិ ហើយ យើងចាប់ផ្តើមសហការគ្នាវិ៍ ជាមួយតាម៉ុក តែម្តង ឬយ៉ាងម៉េចកំលាំងហ្នឹង?

វ៉ែន៖ សហការវិ៍ ។

ដានី៖ អ៊ំវិ៍ដែរ?

វ៉ែន៖ ជាមួយរដ្ឋាភិបាល បោះនៅផ្លូវទេ ហើយរដ្ឋាភិបាលរៀបចំកំលាំងខ្មែរក្រហមហ្នឹងទៅវិ៍ ពួកតាម៉ុក ។

ដានី៖ អ៊ំទៅវិ៍ដែរ? អ៊ំដឹកនាំកំលាំងទៅវិ៍ដែរ?

វ៉ែន៖ ទៅ ។

បូលី៖ ខាងរដ្ឋាភិបាលអ្នកណាគេដែលចុះមកជាប់ជាមួយកងទ័ព វិ៍ជាមួយកងទ័ពពីណាគេ?

វ៉ែន៖ ទេ មេបញ្ជាការខ្ញុំចាំតែម៉ាត់ សិលា ។

ដានី៖ សិលា?

វ៉ែន៖ ម៉ាត់ សិលា ។

បូលី៖ ចុះឈ្មោះអី វ៉ាន់ថន ដែលលឺទេ?

វ៉ែន៖ ទេ វ៉ាន់ថន ខ្ញុំជួបបានម្តង ។

បូលី៖ ចូលមកម្តង?

វ៉ែន៖ ជួបម្តងនៅទំនប់ជាមួយ ជា កែវ ដល់អីចឹងគាត់ទៅវិញ ។

បូលី៖ គាត់អត់មកបន្តវិ៍ទៀតទេ?

វ៉ែន៖ អត់ទេ ។

ដានី៖ មានតែម៉ាត់ សិលា ទេដែលមក? ដែលជាមួយអ៊ំៗជាប់គ្នាតែម្តង?

វ៉ែន៖ គាត់នៅនេះ គាត់នៅថ្លូវ ។

ដានី៖ ឥឡូវគាត់នៅណា?

វ៉ែន៖ ឥឡូវអត់ដែលឃើញទេ តាំងពីនោះមក ។

ដានីៈ ចុះស្រី ឌឹក គាត់មកជាមួយដែលអត់ទេ?

វ៉ែនៈ អត់ទេ អត់ឃើញទេ ។

បូលីៈ នៅខាងក្រោយ?

វ៉ែនៈ បាទ!

បូលីៈ ប៉ុន្មាននាក់កំលាំងរដ្ឋាភិបាលចុះមកវ៉ៃហ្នឹង? ប៉ុន្មានកងពល ឬប៉ុន្មានវរៈ?

វ៉ែនៈ មិនសូវឃើញច្រើនប៉ុន្មានដែលទេ តែនៅតាមបន្ទាយមិនដឹង តែនៅនេះឃើញតិច ។

បូលីៈ អីចឹងកំលាំងដែលវ៉ៃផ្ទាល់ហ្នឹងកំលាំងខ្មែរក្រហមទេ ដែលវ៉ៃជាមួយតាម៉ុក?

វ៉ែនៈ បាទ!

បូលីៈ មិនមែនកំលាំងទ័ពរដ្ឋាភិបាលទេ?

វ៉ែនៈ កងទ័ពរដ្ឋាភិបាលផង ខ្មែរក្រហមផង ។

បូលីៈ មួយណាច្រើនជាងបើប្រៀបធៀបទៅ?

វ៉ែនៈ ប្រហែលតែគ្នាទេ ។

បូលីៈ តែខាងរដ្ឋាភិបាលអ្នកគាំទ្រអាវុធគ្រប់បែបយ៉ាង?

វ៉ែនៈ បាទ!

បូលីៈ ពេលហ្នឹងមានប្រើយន្តហោះទេ?

វ៉ែនៈ អត់ទេ អត់មានទេ ។

បូលីៈ អត់មានប្រើយន្តហោះបាញ់ពីលើ? ទម្លាក់គ្រាប់បែក?

វ៉ែនៈ អត់មានទេ ។

បូលីៈ ទ័ពថ្មើរជើងសុទ្ធតែម្តង?

វ៉ែនៈ បាទ!

បូលីៈ ប៉ុន្មានថ្ងៃបានវ៉ៃរុញតាម៉ុក ឡើងដល់លើភ្នំ?

វ៉ែនៈ មិនចាំថ្ងៃទេ ។

ដានីៈ តែវ៉ៃយូរទេ? ដូចថាយើងចាប់ផ្តើមវ៉ៃរយៈពេលប៉ុន្មាន បានយើងគ្រប់គ្រងបាន?

វ៉ែនៈ វ៉ៃមកដល់១០៥នេះ វ៉ៃតែមួយថ្ងៃទេ បានកាំភ្លើងដេកា៧៥, ដេកា៨២ ឡើងលើភ្នំនោះ ដល់អីចឹងឡើងលើភ្នំកងទ័ពរដ្ឋាភិបាលខ្លះ ខ្មែរក្រហមខ្លះ សល់ប៉ុន្មានពួកខ្មែរក្រហមចាប់ពីក្រោយ ទៅវ៉ៃពីលើវិញ បានក្រោមនេះចាប់ផ្តើមថយខ្សោយៗទៅ ។

ដានីៈ ឆាប់ដែរ?

វ៉ែនៈ ឆាប់ ។

ដានី: ដល់ពេលយើងវ៉ៃបានហើយ យើងចាប់ផ្ដើមយ៉ាងម៉េចទៅ? យើងរៀបចំភូមិ-ស្រុកយ៉ាងម៉េចទៅ? ពេលដែលយើងវ៉ៃបានឈ្នះហើយ?

វ៉ែន: ដូចជាមិនមានរឿងអីផងទេ គ្រាន់តែជាគំរោងដំបូង ជុំ ជាតិ នេះឲ្យទទួលទាហានទៅនៅរតនគិរី ឧត្ដមសេនីយ៍ផ្កាយ១ ហ្នឹងតាមគាត់ខ្ញុំទេ។ ហើយម៉ាត់ សិលា ហ្នឹងហៅខ្ញុំទៅជួបធ្វើការ តាំងពីម៉ោង៧ដល់ម៉ោង១២យប់។

បូលី: ធ្វើរឿងអីអ៊ំ?

វ៉ែន: ធ្វើការរៀបរយ ចាត់តាំងកំលាំង ហើយខ្ញុំគាត់ឲ្យទទួលខុសត្រូវស្រុកត្រពាំងប្រាសាទនេះធ្វើចៅហ្វាយស្រុកតែម្ដង ខ្ញុំថាទេ ខ្ញុំឈប់ហើយ។

ដានី: អ៊ំឈប់?

វ៉ែន: បាទ! ប្រកែកៗឡើងគាត់ខឹងខ្ញុំ ខ្ញុំថាខ្ញុំលែងចង់ធ្វើអីហើយ សុំមករស់នៅជាមួយប្រពន្ធកូនបានហើយអរហើយ។ អត់ទេ អត់បានទេ ដល់យូរៗទៅតាជុំ គាត់នៅអាល័យនិយាយឲ្យស្មោះត្រង់ មិនចង់បែកគ្នាយើងទេ មិនចង់ទៅរស់នៅរតនគិរី ស៊ុំង ត្រែង ឧត្ដមសេនីយ៍ផ្កាយ១ ដូច្នេះគាត់សុខចិត្តនៅធ្វើស្រុកនៅនេះ អីចឹងសុំគេចៅហ្វាយស្រុកទៅខ្ញុំអត់ធ្វើ។

បូលី: អ៊ំធ្វើអីវិញពេលហ្នឹង?

វ៉ែន: ខ្ញុំធ្វើរងគាត់។

បូលី: ចៅហ្វាយស្រុក?

វ៉ែន: បាទ!

បូលី: រងមានប៉ុន្មានពេលហ្នឹង?

វ៉ែន: រងមានខ្ញុំ មានខ្មោចជឿន។

ដានី: យ៉ោក ជឿន?

វ៉ែន: ហ្នឹងហើយមានខ្ញុំ, យ៉ោក ជឿន ហើយសៅ ថាន ហើយជុំ ជាតិ។

ដានី: អ៊ំជុំ ជាតិ គាត់ធ្វើអភិបាល ហើយអ៊ំអភិរង ៣នាក់?

វ៉ែន: បាទ! ៣នាក់។

ដានី: តាំងពីឆ្នាំណាមកហ្នឹង?

វ៉ែន: តាំងពីដោះស្រាយចប់ទំនាស់រៀបរយ។

ដានី: អ៊ំធ្វើអភិបាលរងដល់ឆ្នាំណា បានអ៊ំ?

វ៉ែន: មិនចាំទេ តែខ្ញុំរ៉ៃត្រែតប៉ុន្មានឆ្នាំហើយ។

ដានី៖ ប៉ុន្មានឆ្នាំហើយ?

វ៉ែន៖ ៣-៤ឆ្នាំហើយ ។

ដានី៖ អ៊ីត្រឹមតែ៣-៤ឆ្នាំហើយបានអ៊ីចូលទៅខាងក្រុមប្រឹក្សាវិញ?

វ៉ែន៖ បាទ!

ដានី៖ អ៊ីចឹងអ៊ីពួកខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំអ៊ីទៀតហើយ អ៊ីមានអីចង់បញ្ជាក់បន្ថែមនូវអ្វីដែលពួកខ្ញុំអត់បានសួរនាំទេ?

វ៉ែន៖ បាទ! អត់មានទេ ។

ដានី៖ អ៊ីចឹងខ្ញុំអរគុណច្រើន ដែលបានចំណាយពេលជិត២ម៉ោង ដែលអនុញ្ញាតពួកខ្ញុំសួរនាំទាក់ទងពីបទពិសោធន៍អ៊ី អរគុណច្រើន ។

វ៉ែន៖ បាទ!

ចប់